ភ្នំពេញសុវិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា ទាំងអក្សរសាស្ត្រ ជោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ដិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ដិត នៅ
ពុទ្ធសាសនបណ្ដិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត ហ៊ាង-ស៊ីម អ្នកគ្រូតម្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

បញ្ជីរឿង

		ទំព័រ
ផ្នែកអក្សរសាស្ត្រ		
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម. . .	សេចក្ដីសង្ខេបអំពីពោលផ្សេងៗ នៃពង្សាវតារខ្មែរ	៣៩៥
" "	ពង្សាវតារចិន (តមក)	៤០៣
ព្រះគ្រូសំរិសោភ័ណ កឹម-ភូ . .	រឿងកុមារពីរនាក់ជាមិត្តនឹងគ្នា (តមកនឹងចប់)	៤១៥
ឃុនឧត្តមប្រឹជា ជាប-ពិន. . .	អធិប្បាយសុភាសិតខ្មែរ (តមក).	៤២៣
ឧកញ៉ាទេពតាទូរ ក្រសេម. . .	រណ្ណតត៌ ឧភយណ៌ ទសវារ (តមក). .	៤៣១
ផ្នែកដំណឹងសាសនា		
ព្រះជាឡាត់ពោធិកម យ្ហរ-ប៊ុណ្ណា.	ភណ្ឌុតិណ្ដុកជាតក	៤៣៦
លោកគ្រូព្រះអាចារ្យ ជ៉ាង-ទាត់.	ឥរិយសច្ចជាពុទ្ធភាសិត (តមក)	៤៤៥

ឆ្នាំទី ១៣ — លេខ ៨ ខែអ្ងីត ឆ្នាំ ១៩៤៥ — ដំណៃជាវ: ១ ឆ្នាំ ១៥ រៀល ។

សេចក្ដីសង្ខេបអំពីគោលផ្សេងៗ នៃពង្សាវតារខ្មែរ

ឃ្លងនិពន្ធមន្ត្រីញ៉ុក-ថែម

(ដកស្រង់យកមកអំពីសៀវភៅរបាយការរបស់សាលាបារាំងសែស
នៅចុងបូព៌ាប្រទេសភាគទី ១៨ ក្នុងឆ្នាំ ១៩១៨)

គោលចារឹកផ្សេងៗ សម្រាប់ពង្សាវតារខ្មែរយើង គេបានដោយកម្រពន់ពេក ។ បណ្ដាសំណៅពង្សាវតារខ្មែរ ដែលគេបានចារឹកទុក ទាំងស្លឹករឹតក្ដី ទាំងក្រាំងសៀវភៅក្ដី ក៏កម្រមានច្បាប់ណាមួយល្មមចាប់យកជាគោលពង្សាវតារបានឡើយ ច្រើនតែមានរឿងរ៉ាវមិនហូរហែតាំងពីដើមរហូតមក បើជាសេចក្ដីជាន់ចាស់ ក៏ច្រើនតែមានសេចក្ដីដំណាលជាទំនងរឿងព្រេងច្រើនជាងសាច់ពង្សាវតារ ថែមទាំងមិនមានប្រាប់សករាជឆ្នាំខែថ្ងៃសោះឡើយក៏មាន ។

សាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានប្រឹងស្រាវជ្រាវរកពង្សាវតារខ្មែរ ដែលមាននៅក្នុងទីតំបន់ផ្សេងៗ បានច្រើនល្មមរៀបចំរក្សាទុកក្នុងបណ្ណាល័យរបស់សាលា ។ ឯគោលពង្សាវតារអស់នេះ មានពីរប្រភេទ គឺមួយប្រភេទជាពង្សាវតាររបស់ត្រកូលនីមួយៗ ឬរបស់វត្តទាំងឡាយ ។ មួយប្រភេទទៀត មានលក្ខណៈជារបៀបកដការដំណាលពីពង្សាវតារស្រុកខ្មែរ ឬពោលពីរឿងរ៉ាវ របស់ត្រកូល (រាជក្សត្រ, ពជពង្សាវតារ) ។

ចណ្ណាល័យរបស់សាលាមានសំណៅពង្សាវតារចាំងពីប្រវត្តិ ហៅថាពង្សាវតារស្រុកសំបុត ដំណាលរឿងក្នុងស្រុក ១ សៀវភៅ ពង្សាវតារ ដំណាលពង្សាវតារបស់ត្រកូលមន្ត្រី ចាប់តាំងពីកាលព្រះស្រីសុព័ណ្ណ (ខាងដើមសតវត្សទី ១៧) រហូតមកដល់កាលព្រះអង្គចន់ (១៨០៦-១៨៣៤)១ ។

ឯព្រះកាដនិពន្ធពង្សាវតារក៏មានជាពីរផ្នែក គឺ ១ ផ្នែកសរសេរក្តីជារឿងត្រៃនដែលពោលអំពីរឿងកំប៉ាវផ្ទង ១ ដែលកន្ទងមកហើយក្នុងស្រុកខ្មែររហូតដល់សតវត្សទី ១៤ ។ មួយផ្នែកទៀត ជាផ្ទៃរឿងពង្សាវតារ ចាប់ផ្តើមតាំងអំពីតណ្ណាលសតវត្សទី ១៤ កាលព្រះបាទនិព្វានបទ ។

ផ្នែកទី ២ នេះ គេបានតែងឡើងមុនផ្នែកទី ១ ។ ឯសេចក្តីប្រែជាន់ចាស់បំផុតជាសេចក្តីប្រែដែលលោក ហ្ស-គានីអេ បានប្រែពុតមក ប៉ុន្តែមាននៅឯក្រុងបាងកកក្នុងហ្ស ព្រះសម្ភូតវង្ស ញ្ញាណ មានចំណែក ១ ជាសេចក្តីប្រែជាភាសាសៀម ជាសំណៅរៀបរៀងជាន់ចាស់ ដែលព្រះកុណ ព្រះអង្គអេង បានថ្វាយសំណៅដល់មហាក្សត្រស្រុកសៀមកាលពីកន្លងមកនៅ ១៧៩៥ ។ ចំណែកពង្សាវតារនេះ ក៏មានសេចក្តីសង្ខេបខ្លីពេក ប៉ុន្តែមានហេតុការណ៍ថ្មីៗ ហើយមានការប្រតិបត្តិពិស្តារគ្រាន់បើ ចាប់តាំងពីឆ្នាំ ១៣៤៦ កាលព្រះមហានិព្វានមកអស់ដល់តណ្ណាលសតវត្សទី ១៥ ។

ចំណែកពន្ធ្យវគ្ការផ្នែកនេះ លោកសីដេសបានប្រែចេញជាភាសាបារាំងសេស ខ្ញុំបានប្រែចេញជាខ្មែរភាសា នៅខាងចុងនៃសេចក្តីស្រង់ប្រែនេះ ។

* * *

អ្នកឧកញ៉ាវណ្ណ្យសារពេជ្ជ (ឧ) ជាបណ្ឌិតជាតិខ្មែរម្នាក់ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ក្នុងសម័យព្រះករុណាជាអម្ចាស់ដ៏វិតព្រះអង្គដួង (ព្រះបរមកោដ្ឋ) លោកជាកវីដែលបានតែងពាក្យកាព្យយ៉ាងពីរោះគុកមកជាចំនួនច្រើនរឿង ។ តាមដែលមានរឿងប្រាកដក្នុងសៀវភៅកាយការបស់សាលាបារាំងសេសចុងបូពាប្រទេសឆ្នាំ ១៩១៨ នោះមានសេចក្តីថា អ្នកឧកញ៉ាវណ្ណ្យសារពេជ្ជ (ឧ) ជាព្រះពន្ធគ្ររបស់ព្រះបរមកោដ្ឋព្រះអង្គដួង បានរៀបរៀងរឿងកំសាន្ត១ គុកមកជាច្រើនរឿង[1] ។ នៅឧកាសដែលលោកតែងព្រះពន្ធគ្ររាជការនោះ លោកបានទទួលងារជា "ណ្ណ្យសារពេជ្ជ" ប៉ុន្តែសពពន្ធដែលចាប់ផ្តើមធ្វើការនេះ មិនមានដ៏ធ

---

១ គំរៀងវាតកុល ពោធិកុល សុភាសិត (សុភាសិតនេះ ពុទ្ធសាសនបណ្ឌិត្យចាត់ចងបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយាឆ្នាំ ១៩៤១ បោះចេញជាសៀវភៅដោយឡែកក្នុងឆ្នាំ១៩៤២) មានសេចក្តីប្រែនិងរៀបរៀងជាកាព្យ ១ ទៀតហៅថា (លោកខ្ទេយ្ស) ជារឿងធំមួយ (ដែលបានរៀបរៀងឡើងក្នុងឆ្នាំ ១៧៩៤ កាលនោះលោកមានងារជាវណ្ណ្យសារ) លោកខ្ទេយ្ស ពាក្យកាព្យនេះពុទ្ធសាសនបណ្ឌិត្យកំពុងរៀបចំពុមផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយាសព្វថ្ងៃនេះ ។ ក្រៅពីនេះលោកជាអ្នកជួយរៀបចំតែងរឿងតាមការចាប់ ។

ត្រាកដ ប្រវិហារជាគេបានតែងឡើងនៅវិលរាងកាយ ដែលមានសេចក្តីផ្តើមថា: "ព្រះបាទក្រុងកម្ពុជា ព្រះបាទបរមបពិត្រ ស្តេចប្រថាប់នៅបន្ទាយកែវដែលតាំងនៅខាងត្បូងវត្តព្រះសារីកធាតុ ។ ព្រះករុណាទ្រង់តាំងឧកញ៉ាបវរទេសកជ្ជណ្ណារៃជាមេជាង ទ្រង់ត្រាស់បង្គាប់ឲ្យសាងព្រះពជមន្ទីរ នៅខាងត្បូងព្រះពជមន្ទីរ ឲ្យសាងរូបមនុស្ស ៤ នាក់ ខ្ទាត្តធំ ១ ឈរពីក្នុងជើង ជងខ្ទួនត្រង់ ដៃស្តាំមកផ្ទៃ ។ ទ្រង់ត្រាស់បង្គាប់ឲ្យសាងបេតិយ ១ កំពស់ ៥០ ហត្ថ ចិទមាស លាបថ្នាំក្រហម (ក្រហមស្រស់ហើយ) ទ្រង់ត្រាស់បង្គាប់ឲ្យប្រជុំអស់ទាំងពួកព្រះពជវង្ស-ឧត្តវង្ស ព្រះសង្ឆ ត្រមទាំងមន្ត្រីតូច-ធំទាំងពួកក្នុងព្រះនគរ ទើបទ្រង់មានព្រះពជឧត្តាវបានថា ព្រះពជពង្សវតារបស់ព្រះមហាក្សត្រអំពីបុពណ្ណ រហូតមកដល់ព្រះពជអយ្យកោរបស់ព្រះអង្គនោះបាត់បង់អស់ទៅហើយ ។ ទើបព្រះករុណាទ្រង់មានព្រះពជឧត្តាវបង្គាប់អ្នកឧកញ៉ាវង្សសារពេជ្ជ (ខង) ឲ្យតែងព្រះពជពង្សវតារឡើង ។ មន្ត្រីនេះកាលបានទទួលព្រះពជបង្គាប់ហើយ ក៏ចាត់ចែងតែងព្រះពជពង្សវតារ តាំងអំពីពជ្ជព្រះពជឧត្តាវ ព្រះបរមនិព្វានបទ ព្រះអង្គ" ។

លោក ហ្ស - ការនីអេ មិនដឹងច្បាស់អំពីសកពជសាងកំផមន្ទាយកែវ ១ ខេះឯងដែលគេតែងហៅថាកំនក្ការ ដែលព្រះពជពង្សវតារថា

ក្នុងពេជ្រព្រះអង្គគ្រាង (១៧៧—១៧៨៦) ។ ឯលោកដ៏ឧត្តុង្គ ចាន ក៏ណាត់នៅក្នុងពេជ្រព្រះអង្គចាន់ សេចក្តីពោលនេះមានហេតុផលត្រឹមត្រូវណ្ហ ។ បន្ទាយកែវ ប្រាកដជាព្រះពុជ្ធកំណត់ក្នុងភ្នំពេញ នៅខាងត្បូងវត្តព្រះសារីកធាតុ ឥឡូវនេះហៅថាវត្ត១ណ្ណាលោម ហើយចានកសាងឡើងក្នុងឆ្នាំ ១៨១៣ ។ នៅសម័យនេះហើយដែលលោកនង់ចានទទួលព្រះពុជ្ធឆ្ការ អំពីស្តេចឲ្យតែងរៀបចំព្រះពុជ្ធពង្សាវតារឡើង ។ ព្រះពុជ្ធពង្សាវតារនេះធ្វើចប់កាលពីឆ្នាំ ១៨១៨ ហេតុនេះចានជាក្នុងឆ្នាំនេះឯងដែលគេចានប្រែចេញជាភាសាសៀម ។

ព្រះពុជ្ធពង្សាវតារបស់ផ្សាសាពេជ្ជនៅមានគេចម្លងតា ។ មានជាខ្ចប្ច គន់ដ៏ម្ចាស់ជាវិលាយ ជាឯកសារនាង៖ពង្សាវតារ ១ ដែលពួកអ្នកបរទេសអាចស្វែងរករឿងរ៉ាវសាវតារក្នុងស្រុកខ្មែរចាន ។ ពង្សាវតារនេះហើយដែលទ្រង់ - ម៉ាញ - យ៉ាង នាំចូលទៅក្នុងក្រុងវ៉ ហើយមន្ត្រីក្នុងពុជ្ធសំណាក់ ៣ នាក់ចានប្រែចេញជាភាសាយួនហៅឈ្មោះថា ការ—ម៉ាន់ គ្រីក ។ ពង្សាវតារនេះហើយ ដែលព្រះបាមង្ក្ដុជ ទ្រង់ចង្ហាប់ឲ្យប្រែចេញជាភាសាសៀម ក្នុងឆ្នាំ ១៨៥៥ ត្រាមការត្រួតត្រាយុនសុន្ទរ ហៅជាចង់ហ្ការ៉ាមណ៍ ហើយតមក គេចានចាប់ចោះពុម្ពឡើងជាដំបូង ក្នុងឆ្នាំ ១៨៦៨ ហៅថា ពង្សាវតារខ្មែរ តាំងពីនោះមកគេចានចោះពុម្ពជាច្រើនលើក នៅចុងបំផុត គេចាន

ចោះពុម្ពក្នុងសៀវភៅប្រជុំពង្សាវតារ (១៩១៤) ។ មានពង្សាវតារបស់
វង្សារពេជ្ជ (១) ១ ទៀត ដែលពួកចូតដ៏ឡាត្រែកបានកត្ត្រាមកជាសេចក្ដីជាន់ចាស់ប្រហែលពីឆ្នាំ ១៧៣៩ ដល់ ១៧៨៥ មានសេចក្ដីជាប្រយោជន៍ច្រើន តែមិនពេញ ១ ខ្សែទេ ។ សេចក្ដីនេះមិនមានមានប្រែជាភាសាសៀមឬភាសាយួនទេ ប៉ុន្តែឥឡូវនេះ មានសំណៅពង្ស-វតារមួយជាភាសាខ្មែរនៅគង់រង់គ្រប់គ្រាន់ក្នុងវត្តសត្ថប្ដ (ស្រុកស្ពាន) ហើយបណ្ណាល័យ (របស់សាលា) ក៏បានចម្លងទុក ១ ចប់ ។ សំណៅពង្សាវតារនេះ មិនមានអារម្ភកថាប្រាប់អំពីស្ដេចត្រែងពាជ្ញនឹងឈ្មោះអ្នកតែងទេ ប៉ុន្តែបើយកទៅប្រៀបធៀបនឹងសំណៅរបស់ដ៏ឡាត្រែ នឹងសេចក្ដីប្រែជាសៀម អាចយល់បានថាចេញមកពីប្រាប់ដើមតែមួយ មានសេចក្ដីសារស័ព្ទរហូតមកដល់ពេលចំរ៉ូតនៃព្រះបាទសម្ដេចព្រះនរោត្តមក្នុងឆ្នាំ ១៨០៤ ។

រឿងរៀបចំតែងរបស់លោកនង ដែលលោកដ៏ឡាត្រែកត្រមកបាន ១ ខ្សែតែមិនចប់នោះ ប្រហែលជាកត្រមិនបានទៀតទេ ក្នុងឆ្នាំ ១៨៦៩ ព្រោះឆ្នាំនោះព្រះបាទសម្ដេចព្រះនរោត្តម ទ្រង់បង្គាប់ឲ្យគ្រូមនិពន្ធតែងពង្សាវតារក្នុងប្រទេសរបស់ទ្រង់ ។ មាន ២ ខ្សែទៀតតែងមិនចប់ដែរ គេមិនស្គាល់ឈ្មោះអ្នកតែងទេ មាននៅក្នុងព្រះពជ្ជកំ ( ) ក្នុងភ្នំពេញ (ព្រះឃ្លាំងហ្ជ) នៅបណ្ណាល័យ (របស់សាលា) មានចម្លាប់ចម្លង ១ ចប់ ។

ក្រៅពីឆ្នាំនេះ នៅចុងឆ្នាំ ១៨៦៨ មានច្បាប់ពង្សាវតារផ្សេងទៀត មានសេចក្ដីពិស្ដារទូលាយ នៅព្រះឃ្លាំងហ្លួង មាន ១ ច្បាប់ចប់សព្វគ្រប់ រួមជា ៦ ក្រាំង ហើយនៅបណ្ណាល័យមានច្បាប់ចម្លង ១ ចប់ ។

មានចំណែកពង្សាវតារផ្សេង ៗ ទៀត តាំងពីរាជ្យស្ដេចនិព្វានបទ មក ដែលគេបានរកឃើញនៅស្រុកខ្មែរនោះ តាមបញ្ជីរបស់សាលាបារាំងសែសមានដូច្នេះ:

១ — ចំណែកមួយតាំងពីឆ្នាំ ១៥៩០ ដល់ ១៧២៩ គេបានរក្សាទុកក្នុងព្រះឃ្លាំង ។

២ - ចំណែកមួយតាំងពីឆ្នាំ ១៥៤៧ ដល់ ១៨០២ លោក អេឌូអារ ទ័ហ៊ុយបែរ បានឃើញនៅក្រុងភ្នំពេញ មានសេចក្ដីប្លែកផ្សេងពីច្បាប់ឯទៀត ៗ ហើយមានសេចក្ដីទំនងពិតប្រាកដល្មមសមគួរផង ។

៣ - ចំណែកមួយពីឆ្នាំ ១៥៥៧ ដល់ ១៨៨០ រួមជាសៀវភៅ ១ លាយចម្រុះសំណៅផ្សេង ៗ លោកអាត់ល័ក្លែរបានឃើញ ។

៤ - ចំណែកមួយបានមកពីវត្តព្រះរដេង (ស្រុកកំពង់សៀម) មានសេចក្ដីផ្ដើមតាំងពីកសាងក្រុងលង្វែក ហើយបញ្ចប់មុនពួកសៀមវាយយកបានក្រុងបន្ទិច ។

៥- ចំណែកមួយមិនសូវមានប្រយោជន៍ធំដុំទេ ចាប់តាំងពីសតវត្សរ៍ទី ១៩ មក ។

ផ្នែកវៀងត្រែង ដែលមានសេចក្តីប្រាកដក្នុងព្រះពាជតង្ស្រាតារ នោះសម្តេចព្រះសុគន្ធ ប៉ាន ដែលបង្កើតគណធម្មយុត្តិឡើង ជាអ្នកតែងនិងរៀបរៀងឡើងជាដំបូង ។ មួយវិញទៀត លោក ហ្ស-តានីអេ និយាយបញ្ជាក់ថា "មានសេចក្តីផ្នែកវៀងជាពង្ស្រាតារមួយ ដែលចាប់ផ្តើមឡើងកាលពីឆ្នាំ ១៣៤៦ ដែលគេបានរកឃើញវិញនៅក្នុងដៃពួកខ្មែរ" ។ សេចក្តីនេះ លោកអ៊ីមានីអេ ថាជាសេចក្តីរៀបរៀងរបស់ព្រះសុគន្ធដែរ ។ សេចក្តីរៀបរៀងរបស់លោកនេះនៅខាងក្នុងឆ្នាំ ១៨៧៨ ។ កំណត់នេះ ត្រូវកត់ជាព្រះពាជបុត្រ ១ អង្គ របស់ព្រះអង្គដួង ព្រះនាមព្រះអង្គម្ចាស់នពរ៉ត្ន ទ្រង់ចាប់ទទួលឡើងហើយតមកសម្តេចព្រះសុគន្ធបានបន្ថែមបន្ថយឡើងទៀត ។ សេចក្តីចំឡងអំពីច្បាប់ស្ថាបនាព្រះហស្តរបស់ព្រះអង្គម្ចាស់នេះ មានទៅក្នុងវត្តចាំងឡាយជាច្រើនតាមដងទន្លេធំ ដូចជានៅហ៊ានជ័យនិងវត្តសត្តប្ញជាដើម ។ សំណៅពង្ស្រាតារនេះ បណ្ណាល័យបានចម្លងទុក ១ ចប់ដែរ ។ ក្នុងសេចក្តីផ្តើមនោះដែលគួរនាំមកពោលក្នុងទីនេះ អ្នកនិពន្ធបានទាញយកមកតាមទីផ្សេង ។ ដូចតទៅ:

"ក្នុងឆ្នាំ ១៨៧៨ នៅថ្ងៃ ១ កើតខែផល្គុន ព្រ-អង្គម្ចាស់នពរ៉ត្នជាព្រះពាជបុត្រ ព្រះអង្គដួង ទ្រង់ព្រះចិន្តាថា គួរតែមានព្រះពាជពង្ស្រាតារសម្រាប់ស្រុកខ្មែរនេះឡើង ដើម្បីឲ្យបានបេះដូងកាលគ្នា ។ (ហេតុ)

ប្រាជ្ញនិពន្ធមន្ត្រី ញ៉ុក-ថែម

(រៀបរៀងតមក)

អំពីព្រះពុទ្ធសាសនា

ការដែលពួកមនុស្សព្រៃលុកលុយចូលមកក្នុងខេត្តដែនចិន និងការដែលពួកកេ-យូកេនទៅតាំងនៅក្នុងម៉ុងហ្គូលីនោះ ជាការបើកផ្លូវដែលធ្លាប់ទៅមករវាងឥណ្ឌានឹងបូព៌ាប្រទេស លុះរាជវង្សតូបៈ មានអំណាចឡើង ក៏គិតគូរកែកៃរឿងនេះ ។ ក្នុងឆ្នាំពុទ្ធសករាជ ៩៩១ ពួករាជវង្សតូបៈ ទើបមានជ័យជំនះឈ្នះពួកកេ - យូកេន ហើយបានផ្សាយអំណាចចូលទៅក្នុងអាណាចក្រតក្កាវៀន និងខាងអាណាចក្រកាក់គារ, កុលជាទីងក៏ច-គារ តាំងពីនោះមក ផ្លូវគមនាគមក្នុងអាណាចក្រចិនក៏បានស្រួលឡើងវិញ ស្ពានមេត្រីខាងផ្លូវសាសនាក៏ត្រឡប់មានឡើងវិញដែរ ។

មកដល់សម័យនេះ យើងអាចពោលបានថា អ្នកដែលជាធំលើឬមានជ័យជំនះឈ្នះស្រុកចិនយ៉ាងពិត ៗ នោះ មិនមែនពួកអ្នកចម្បាំងតូបៈ ប្តុង-ជី ឬឡោ-សឺទេ គឺព្រះសម្មាសម្ពុទ្ធរបស់យើងរាល់គ្នានេះឯង ដោយបានផ្សាយពុទ្ធអាណាចក្រចូលទៅរហូតខេត្តដែនចិនតាំងពីលើចុះមកក្រោម ។ ក្នុងពុទ្ធសករាជ ៨៧៨ នៅរាជសំណាក់ណាន-គិង បានចេញព្រះរាជបញ្ញត្តិប្រកាសព្រះរាជឧង្ការរបស់ព្រះចៅក្រុងចិន ទទួល

យកព្រះពុទ្ធសាសនាជាសាសនារាជការរបស់អាណាចក្រទ្រង់ ហើយក្នុងឆ្នាំពុទ្ធសករាជ ៩២៤ ព្រះបាទស៊ុន-ហៀវវ៉ូទី ទ្រង់កសាងហោព្រះពុទ្ធរូបឡើងក្នុងព្រះរាជវាំងជាដំបូងបំផុត ។ ក្នុងរជ្ជសម័យតមក ព្រះបាទដិន-ង៉ានទី គ្រងរាជ្យ ទ្រង់បានចាត់បញ្ជូនសមណទូតសំខាន់របស់ចិន គឺលោកហ្វា-ហៀន ចូលទៅប្រទេសឥណ្ឌា កាលពីពុទ្ធសករាជ ៩៤២ ដូចមានពោលទុកក្នុងប្រវត្តិសាស្ត្រឥណ្ឌា ។

នៅដែនដីភាគខាងជើងនោះ ជាន់ដំបូង ពន្ធីរស៊ីវៃលទ្ធិខុង-ជី នៅចំរើនរុងរឿងនៅឡើយ ហើយព្រះបាទតួប:ថៅ តាំងព្រះអង្គជាសត្រូវនឹងព្រះពុទ្ធសាសនាថែមទៀតផង ក្នុងឆ្នាំពុទ្ធសករាជ ៩៨៧ ទ្រង់ឲ្យបំផ្លាញ សាលា, វិហារ, រោងឧបោសថ និងកាប់សម្លាប់ពុទ្ធសាសនិកជនអស់ទៅជាច្រើន គម្ពីរដីកាផ្សេងៗ ក៏ឲ្យយកទៅដុតចោលទាំងអស់ ហើយចាប់ពួកភិក្ខុសម្លាប់ចោល មុះគួរឲ្យសង្វេគជាអនេក ។ អំណើះកាលតមក ទើបមានព្រះមហាក្សត្រមួយអង្គទៀតទ្រង់ព្រះនាមព្រះបាទតួប:ស៊ុន ដែលបានគ្រងរាជ្យតាំងពីពុទ្ធសករាជ ៩៩៥ ដល់ពុទ្ធសករាជ ១០០៨ ទ្រង់បានធ្វើការទាំងពួងផ្ទុយនឹងដែនដីមុនៗ មក គឺព្រះមហាក្សត្រអង្គថ្មីនេះ ទ្រង់ជ្រះថ្លាយ៉ាងមុតមាំក្នុងព្រះពុទ្ធសាសនា ។ ក្នុងឆ្នាំពុទ្ធសករាជ ៩៩៥ ជាឆ្នាំដែលព្រះចៅដែនដីអង្គនេះឡើងគ្រងរាជសម្បត្តិនោះ ទ្រង់ចេញប្រកាសមិនឲ្យអ្នកឯណាប្រទូសរ៉ាយ ឬបំផ្លាញ

វត្តកសាងផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ហើយតមកទៀត ព្រះពុទ្ធសាសនាក៏ក្លាយទៅជាសាសនាពុជការបស់ព្រះមហាក្សត្រពុជវង្សគ្រប: គឺជាសាសនាសម្រាប់ប្រទេសចិនទៅវិញទាំងដើមទាំងមូល ។ ព្រះបាទគ្រប:ស៊ីន ជាព្រះមហាក្សត្រដែលជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងពិតៗ. ដល់ទៅទ្រង់ការព្រះកេសាដូចយ៉ាងភិក្ខុ នៅវេលាដែលទ្រង់គ្រងរាជ-សម្បត្តិនៅឡើយ ហើយនៅទីបំផុត ក៏ទ្រង់លះបង់រាជសម្បត្តិទ្រង់ព្រះផ្នួសទៅ ។ ក្នុងរជ្ជសម័យនៃព្រះមហាក្សត្រអង្គនេះ មានការកសាងវាលវត្តផ្សេងៗ ខុតក្នុងព្រះពុទ្ធសាសនាជាច្រើន ។ ព្រះបាទគ្រប:យ៉ុងដែលគ្រងរាជសម្បត្តិជាដំណតមក ក៏បានបោះបង់ទ្រង់ព្រះផ្នួសដែរ ។ កាលពីឆ្នាំពុទ្ធសករាជ ១០១៣ ហើយព្រះមហាក្សត្រតមកទៀតទ្រង់ព្រះនាមគ្រប:ក្ង គ្រងរាជសម្បត្តិក្នុងរវាងពុទ្ធសករាជ ១០៤៣ ដល់ពុទ្ធសករាជ ១០៥៨ នោះ ទ្រង់បានកសាងព្រះវិហារ ៣ ខ្នង ទំនងវត្តផ្សេងៗទៀតខុតក្នុងព្រះពុទ្ធសាសនា ។ លុះតមកដល់រជ្ជសម័យព្រះនាងហ្ជូ-ដីទ្រង់គ្រងរាជសម្បត្តិក្នុងរវាងពុទ្ធសករាជ ១០៥៩ ដល់ពុទ្ធសករាជ ១០៧១ កាន់តែទ្រង់ជ្រះថ្លាក្នុងពុទ្ធសាសនាច្រើនឡើងទៀត. ក្នុងរាជ្យរបស់ព្រះនាងនោះ មានការកសាងវិហារ ១ ជ្ញាសម ទំនងធ្វើបុណ្យទានផ្សេងៗយ៉ាងធំ ។ ជាទ្ធមសម្បត្តិក្នុងវត្តឲ្យកាន់តែកុះការរៀងជានិច្ច ទ្រង់បានចាត់ចញ្ជូនសមណទូតទៅប្រទេសឥណ្ឌា ហើយនាំយកគម្ពីរដីកាផ្សេងៗ

របស់ព្រះពុទ្ធសាសនាមកចូលប្រទេសចិនមានចំនួនដល់ទៅ ១៧០គម្ពីរ ។ សេចក្តីជ្រះថ្លាយ៉ាងខ្លាំងក្លានេះ នាំឲ្យពួកអ្នកប្រាជ្ញចិនដែលគោរពលទ្ធិខុង-ជឺមានសេចក្តីស្អប់ខ្ពើម ហើយបានគប់គិតគ្នាដកយកព្រះនាងចេញពាកពជបល្ល័ង្ក កាលដែលព្រះនាងទិវង្គតទៅនោះ មានចំនួនវត្តក្នុងព្រះពុទ្ធសាសនានៅក្នុងក្រុងលោ-យ៉ាង ដែលជាទីក្រុងមួយប៉ុណ្ណោះ ដល់ ៥០០វត្ត ។

សម្ព័ប្រទេសចិន បានបែងចែកជា ២ ភាគដូច្នេះហើយក៏ដោយ អាការប្លែកផ្សេងគ្នារវាងពួកគួប:នៅក្រុងលោ-យ៉ាង និងពួកចិនសុទ្ធនៅក្រុងណាន-គិងនោះ ក៏កាន់តែបាត់លេចរលាយអស់ទៅបន្តិចម្តងៗ ត្រាតែមើលឃើញបែបផែនប្រហែលៗគ្នាឡើង ។ ឯសេចក្តីព្យាយាមរបស់គួប: ប៉ងនឹងយកជ័យជំនះខេត្តដែនផ្សេងៗនៅភាងទន្លេយ៉ាំង-សេក្តី សេចក្តីព្យាយាមរបស់ពួកចិនសុទ្ធ ដែលគិតទៅដណ្តើមយកខេត្តហ៊ូ-ណានត្រឡប់មកវិញក្តី សុទ្ធតែមិនសម្រេចទាំងសងខាង ទើបទាំង ២ នគរក៏នាំគ្នារក្សាគ្រប់គ្រងស្រុកទេសដោយរៀងខ្លួនទៅ ហើយបានកែប្រែរបៀបចំនៀមប្រពៃណីឲ្យមានលក្ខណៈប្រហែលៗគ្នាឡើង រហូតដល់គំនិតយោបល់យល់ឃើញខាងរបៀបអក្សរសាស្ត្រ និងការរចនាផ្សេងៗ សឹងមានទំនងប្រហែលៗគ្នាដែរ ។ ព្រះបាទលៀង-វូទី គ្រងរាជសម្បត្តិនៅនគរណាន-គិង តាំងពីឆ្នាំពុទ្ធសករាជ ១០៤៥ ដល់

ពុទ្ធសកពជ ១០៨៤ នោះ ជាព្រះមហាក្សត្រដែលទ្រង់គាន់ព្រះពុទ្ធ-
សាសនាយ៉ាងខ្លាំងខ្លួនម៉ាមួន ប្រហែលនឹងព្រះនាង ហ្ស៊ូ-ដ ដែលគ្រង
ពជ្យនៅក្នុងសោ យ៉ូងដែរ ។ ប៉ុន្តែព្រះចាន់លៀង-ប្ញ ជាព្រះមហា-
ក្សត្រដែលមានលក្ខណៈ ២ ក្រ គឺជួនកាលទ្រង់សាហាវកាច ជួនកាល
មានមេត្តាករុណា ទ្រង់ធ្វើតាមណាមួយដល់ពួកមនុស្សក៏ច្រើន ប៉ុន្តែទ្រង់
ធ្វើបុណ្យទានក៏ច្រើន ទ្រង់ចាន់ចេញប្រកាសបន្ទរ ឲ្យលើកលែង
ធ្វើទោសប្រហារជីវិតមនុស្ស ។ នៅវេលាដែលទ្រង់ជកកាតៗនោះ
ទ្រង់មិនព្រមសោយសាច់សត្វអ្វីឡើយ ហើយតមក ទ្រង់គេចចៀសវាង
ពីពជ្ជសម្ផត្ថិ ទៅប្រជាប់នៅតែកន្ធ ពួកអាមាត្យមន្ត្រីនាំគ្នាទៅតាម
អញ្ជើញស្តេចឲ្យយាងត្រឡប់មកវិញ តែព្រះចាន់លៀង-ប្ញ ស្តេចមិន
ព្រមចេញពីវត្តសោះ ពាល់តែវង្ហាយកប្ចាក់ទៅជាក់ជួជាវត្ត ជាច្រើន
ទើបស្តេចព្រមចេញពីវត្ត មានទ្រង់ជួចពជ្ជការយកប្ចាក់ទៅ
ទិញប្ដូរសោះ ទ្រង់មកវិញ ។

ក្រៅអំពីព្រះមហាក្សត្រហើយ ប្រជាជនជាតិចិនក៏មានសេចក្ដី
ជ្រះថ្លាយ៉ាងខ្លាំងខ្លួនកន្ធ ព្រះពុទ្ធសាសនាជាច្រើន ហើយថែមទាំងខ្ចាំង
ក្ដាជាងព្រះមហាក្សត្រទៅទៀត ។ ចំនួនដ៏ផ្ទៃមានទ្រង់ខ្ពស់ត្ថ្ងន
នេះឯង គឺកន្ធ ប្រទេសផ្ទៃ សូម្ប៉ីព្រះមហាក្សត្រមានសេចក្ដីជ្រះថ្លា
យ៉ាងម៉ាមនយ៉ាងណាក៏ដោយ ចំណែកខាងសេចក្ដីជ្រះថ្លារបស់ប្រជាជន

មានតែសាបសូន្យថយសន្ធាទៅបន្តិចម្តងៗ ព្រោះតែព្រះពុទ្ធសាសនាបាត់ពន្លឺស្មើពីផ្ទៃផែនដីឥណ្ឌាអស់ទៅៗ ឯចិនមិនមែនដូច្នោះទេ សូម្បីព្រះមហាក្សត្រអង្គខ្លះមិនទ្រង់ជ្រះថ្លានឹងព្រះពុទ្ធសាសនា ហើយលទ្ធិតៅអ៊ីស្ទមានអំណាចច្រើនក្នុងស្រុកចិនក៏ដោយ តែប្រជាជនចិននៅតែមានសេចក្តីខ្ជាប់ខ្ជួនក្នុងព្រះពុទ្ធគុណ ក្រៅពីពួកចិនសុទ្ធហើយនៅមានពួកចិនតាតដែលបារាំងហៅថាតាតា, ក៏មានសេចក្តីជ្រះថ្លាមាំក្នុងព្រះពុទ្ធសាសនាដែរៗ ក្នុងសម័យនេះឯង ដែលពួកសមណៈចិន, បានត្រាច់ចារិកទៅកាន់ពុទ្ធភូមិ ក្នុងដែនទេសឥណ្ឌា ដើម្បីនមស្ការចេតិយស្ថាន ដោយសេចក្តីជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយក្នុងសម័យនេះឯង ពួកអាន់សាសនាព្រាហ្មណ៍ កំពុងមានអំណាចក្នុងឥណ្ឌា បានបៀតបៀនប្រទូសរ៉ាយពួកសមណៈក្នុងព្រះពុទ្ធសាសនា ទើបសមណៈឥណ្ឌាក៏នាំគ្នាគេចរត់ភៀសចេញពីដែនទេសសិន្ធុនឹងទេសគង្គា ចូលទៅជ្រកកោនម្ជប់ត្រជាក់នៅដែនទេសហាង-ហូ នឹងយ៉ាំង-សេ ក្នុងប្រទេសចិនវិញក្នុងរាជ្យពុទ្ធសករាជ ១០៦៨ ព្រះពោធិធម្ម: (ចិនហៅថា តូម៉ោ) បានរត់ពីភ័យអន្តរាយពីឥណ្ឌាចូលទៅក្នុងស្រុកណាន-គិង សម័យនោះព្រះបាទលៀង-វូទីកំពុងគ្រប់គ្រងរាជសម្បត្តិ ហើយទ្រង់ជ្រះថ្លាយ៉ាងហ្មត់ចត់ក្នុងព្រះពុទ្ធសាសនា ទាល់តែបាំងតាំងព្រះនាមថ្វាយថា "ភិក្ខុរាក់មកុដ" ៗ ព្រះបាទលៀង-វូបានចេញទៅក្រុងណាន-គិង [illegible]

ពាសពេញទៅដោយវត្តអារាម ទ្រង់ចេញព្រះរាជប្រកាសហាមមិនឲ្យអ្នកណាមួយសម្លាប់សត្វសែនអ្នកតា (ឬខ្មោចដូនតា) ដែលជាលទ្ធិតៅអ៊ីស្ទ ក្រៅអំពីនេះ ទ្រង់មានព្រះបន្ទូលឲ្យដុតគម្ពីរដីការបស់លទ្ធិតៅអ៊ីស្ទអស់ទៅជាច្រើន ។

ក្នុងគ្រាសម័យនេះ លទ្ធិខុង-ជឺបានគាប់ពន្លឺរស្មីទៅជាចំរៀក តែខាងលទ្ធិតៅអ៊ីស្ទនៅមានអំណាចជាច្រើននៅឡើយ មានសេចក្តីដំណាលថា ក្នុងព្រះពុទ្ធសករាជមួយពាន់ឆ្នាំនោះ បណ្តាគម្ពីរត្រៃសាសនាក្នុងភាសាចិនមានចំនួនប្រមាណ ១០០០ គម្ពីរ ទីងមានលទ្ធិរបស់ខុង-ជឺតែមួយគម្ពីរក៏គ្មាន គឺមានសុទ្ធតែជាគម្ពីរខាងលទ្ធិតៅអ៊ីស្ទ នឹងព្រះពុទ្ធសាសនា ។ ក្នុងសម័យដែលពួកហ្វូនចូលមកគ្រប់គ្រងស្រុកចិននោះ ខុង-ជឺបានទទួលសេចក្តីរាប់អានត្រឹមតែជាអ្នកប្រាជ្ញ ដែលចេះនិពន្ធរឿងយ៉ាងពូកែបំផុតម្នាក់ប៉ុណ្ណោះ តែចំណែកខាងពុទ្ធសាសនាចំរើនរុងរឿងជាទីបំផុត ក្នុងរវាងពុទ្ធសករាជ ៩៩០ ឆ្នាំ មានចំនួនវត្តក្នុងស្រុកចិនច្រើនជាង ១៣,០០០ វត្ត មានពួកភិក្ខុជាជាតិឥណ្ឌាចូលទៅនៅក្នុងស្រុកចិន មានចំនួនច្រើនជាង ៣០០០រូប ទើបជាហេតុនាំឲ្យមនុស្សខ្ជិលគេចវៀះចៀសរាងពីមុខក្រសួងស្រុកទេស ចូលទៅជ្រកនៅក្នុងវត្តជាចំនួនច្រើនណាស់ ហើយមានមនុស្សខ្ជិលច្រអូសចូលទៅជ្រកនៅក្នុងវត្តក៏កាន់តែមានច្រើនឡើងដែរ ហេតុនេះហើយ ក្នុងឆ្នាំពុទ្ធសករាជ ៩៩៥

ផ្ទះបាលចំនួនបញ្ជាក់ថា ត្រូវឲ្យស្រុកមួយមានកូនៅបានត្រឹម ៥០ រូបប៉ុណ្ណោះ តែស្រុកណាមានចំនួនកូនគ្រប់ ៥០ រូបហើយ អ្នកណានឹងបួលទៅបួសទៀតពុំបានឡើយ ។

ពជវង្ស្ត្ចូ:ពីដើមមកនោះ មិនមែនជាជាតិចិនទេ តែបានទទួលសេចក្តីចំរើនតាមបែបចិនកាន់តែច្រើនឡើង។ ហើយក្លាយទៅជាចិនទៅ ប៉ុន្តែតាមធម្មតាស្រុកទេស កាលបើមានសេចក្តីចំរើនច្រើនហើយ ក៏ជល់ទ្ចូ:សេចក្តីសាបសូន្យទៅវិញជាធម្មតា ហេតុនេះហើយបានជាកន្ទ ធ្នាំពុទ្ធសកាជ ១០៧៧ ពជអាណាចក្ររបស់ពជវង្ស្ត្ចូ:ក៏បែកខ្ចែកជា ២ ភាគ គឺវៀតនោះទិសខាងលិច តាំងទីក្រុងនៅស៊ី-ជ៉ាន, ខេត្តបេន-ស៊ី ហើយខាងវៀតនោះទិសខាងកើត តាំងទីក្រុងនៅធាង-ហៅ ក្នុងខេត្ត ហ្ចូ-ណាន ។

អំពីពួកតួកិ

ការដែលពជវង្ស្ត្ចូ:រសាំរសាយសាបសូន្យទៅនោះ ជាហេតុបើកឱកាសឲ្យពួកតួកិ ចាប់តាំងអាណាចក្រឡើងនៅត្រង់ពាក់កណ្តាលទ្ចីបអាស៊ីបាន ។

យើងបានពោលមកខ្ញុ:ហើយថា ពួកជាតិតួកិ ដែលចិនហៅថា ត្ចូ:ស្ចៀ: ជាប្រជាជនមានវៃ្ស្ត្ចស្ចាយចេញមកពីរួ:ហ្ចួន ដែលតាំងនៅខាងកើតអ៊ីលី-ណ ដែនដីក្ចុ:ចន-ហ៊ីក ក្នុងរវាងពុទ្ធសកាជមួយពាន់ធ្នាំ

ពួកនេះបានថយចុះមកខាងត្បូងបន្តិចម្ដងៗ ហើយសំដៅត្រង់មកកេដង ទន្លេគារិមនឹងទន្លេហ្វាង-ហូ ដោយមាននាយកម្នាក់ឈ្មោះប៊ុរតេបេន ជាអ្នកនាំផ្លូវ តែសម័យនេះ ពួកតួកីនៅជាចំណុះពួកកេ-យ៉ូកេន ដែលជាជាតិមញ្ជូនៅគ្រប់គ្រងដែនម៉ុងហ្គោលីតាំងពីពុទ្ធសករាជរវាង ៩៥០ ឆ្នាំ ៗ លុះតមកក្នុងឆ្នាំពុទ្ធសករាជ ១០៨៩ ទើបមានព្រះរាជារបស់ពួកតួកីមួយអង្គព្រះនាមខាន-ប៊ូមេន ឬប៊ូ-មិនខាន តាំងបំបះបំបោរឡើងច្បាំងតទល់នឹងពួកកេ-យ៉ូកេន មានជ័យជំនះទើបចាត់ការបណ្ដេញពួកកេ-យ៉ូកេន ឲ្យបែកខ្ចាត់ខ្ចាយរត់ចូលទៅនៅក្នុងទ្វីបអឺរ៉ុប ៗ ការដែលពួកនេះរត់ចូលទៅក្នុងទ្វីបអឺរ៉ុបនោះ ទុកចោលទីទំនេរដែនម៉ុងហ្គោលីឲ្យពួកតួកី ទើបតាំងពីពុទ្ធសករាជ ១០៨៩ ដល់ពុទ្ធសករាជ ១១២៤ មក ពួកតួកីក៏បានគ្រប់គ្រងខេត្តដែនត្រង់ពាក់កណ្ដាលទ្វីបអាស៊ី ដោយមិនបាច់មានគូសត្រូវមកទទឹងទាស់ឡើយ តាំងពីកំផែងចិនរហូតទៅដល់ស៊ីបារីយ៍ តែកាលដែលព្រះរាជាខានប៊ូ-មេន ក្ស័យព្រះជន្មទៅហើយអាណាចក្រតួកីក៏បែកចេញជា ២ ភាគ គឺបានទៅបុត្ររបស់ព្រះរាជាដែលទិវង្គតទៅ ១ ភាគ បានទៅប្អូនប្រុសរបស់ព្រះរាជានោះ ១ ភាគ ចាប់តាំងពីពុទ្ធសករាជ ១០៩៦ ដល់ពុទ្ធសករាជ ១១១៥ ៗ ការបែងចែកជាពីរភាគនេះ មានសេចក្ដីសុខមកជាវេលាយូរ ទើបអាណាចក្រទាំងពីរកើតប្រណាំងប្រជែងគ្នាឡើង ៗ ពួកដែលទៅទិសខាងលិច បានផ្សាយអំណាចពង្រីក

អាណាខេត្តរហូតទៅដល់ប្រទេសប៉ែរ្ស៍ នៅគ្រានេះពួកតួកិមានអាណាខេត្តដ៏ធំទូលាយ គឺតាំងពីប្រទេសចិនរហូតដល់ប្រទេសប៉ែរ្ស៍ ដែនដីរបស់ពួកតួកិ ទើបក្លាយទៅជាកន្លែងលក់ដូរយ៉ាងសំខាន់ខាងផ្លូវជំនួញ ហើយពួកតួកិក៏ក្លាយទៅជាសត្រូវយ៉ាងសំខាន់របស់ចិន ដូចមានសេចក្ដីសារស័ព្ទក្នុងវគ្គជាលំដាប់តទៅ ។

អំពីរាជវង្សស៊ុយ

រាជវង្សតូច: ដែលបានបែកខ្ញែកគ្នាជា ២ អាណាចក្រដូចពោលមកហើយនោះ លុះមកដល់ព្រះពុទ្ធសករាជ ១១២០ ក៏ត្រឡប់បានមករួបរួមគ្នាជាថ្មីឡើងវិញ មានរាជវង្សថ្មីហៅថារាជវង្សស៊ុយ ដែលបានចាប់តាំងខ្លួនមានឡាក់ហ៊ានឡើង កាលពីឆ្នាំពុទ្ធសករាជ ១១២៤ ព្រះមហាក្សត្រអង្គដំបូងរបស់រាជវង្សនេះ ទ្រង់ព្រះនាមថា យ៉ុង-កៀង បានចាប់ផ្ដើមធ្វើសង្គ្រាមនឹងអាណាចក្រចិនភាគខាងត្បូង កាលពីឆ្នាំពុទ្ធសករាជ ១១៣២ ហើយបានចាប់ព្រះមហាក្សត្រនៃអាណាចក្រចិនខាងត្បូងមកឃុំខាំងទុក តអំពីនោះមក រាជអាណាចក្រចិនក៏បានរួបរួមមូលគ្នាបានឡើងវិញម្ដងទៀត ហើយសេចក្ដីចំរើនរុងរឿង. ដែលធ្លាប់មានមកហើយក្នុងសម័យរាជវង្សហាន ក៏ចាប់ផ្ដើមមានឡើងម្ដងទៀតដែរ ។

ការដែលបានរួបរួមអាណាចក្រចិនជាថ្មីឡើងវិញ សម្រេចក្នុងគ្រានេះ គួរកប់ថាជាការសំខាន់មួយបាន ។ ព្រះបាទយ៉ុង-ទី ព្រះមហាក្សត្រ

អង្គទី ២ កងពលវង្សស៊ីយ ដែលបានគ្រងរាជសម្បត្តិជាវេលា ១៣ ឆ្នាំ គឺកងរវាងពុទ្ធសករាជ ១១៤៨ ដល់ពុទ្ធសករាជ ១១៦០ នោះ ទ្រង់បានចាប់ផ្តើមធ្វើសង្គ្រាមនឹងទ្វីបអាស៊ីត្រង់ភាគឦសាន លេចធ្លាយ ហើយបានចូលលុកលុយប្រទេសឥណ្ឌូស៊ីន, ភ្ជីស្ថាន, គឺថារួបរួមយកអំណាចចាស់របស់ចិនមកវិញបានពាក់កន្លះ ។ ចំពោះប្រទេសឥណ្ឌូស៊ីន ចំណែកដែលជារបស់យួនលើដែលហៅថា ភូមិតំង នោះគ្រាប់ជាចំណុះប្រទេសចិន ទំនងជាប្រទេសថ្ងាយគ្រឿងពលបណ្ណាការ ទើបតែមកតាំងរឹងទ្រឹងតាំងជាអាណាចក្រឥស្សរៈឡើង មុនសម័យពលវង្សស៊ីយគ្រប់គ្រងស្រុកចិនមិនយូរប៉ុន្មានទេ លុះមកកន្លងឆ្នាំពុទ្ធសករាជ ១១៤៨ ព្រះបាទយ៉ុង-ទី ចាត់បញ្ជូនកងទាហានមកជ្រាបជ្រាមប្រទេសយួន ហើយរួបរួមស្រុកយួនមកបញ្ចូលកងពលអាណាចក្ររបស់ទ្រង់ ។ តមកមួយឆ្នាំទៀត កងទ័ពដើងទ័ពរបស់ចិន បានលើកធ្វើដំណើរវាយយកកោះតៃ-វ៉ាន ដែលជាកាំងហៅថាហ្ស៊ីមូសបានទៀត ឥឡូវមកមួយឆ្នាំទៀតអំណាចចិនក៏លូតលាតចូលមកដល់ស្រុកខ្មែរ ឯខាងទ្វីបអាស៊ីត្រង់ភាគឦសានទៀត ក៏ត្រូវកងទ័ពចិនជ្រាបជ្រាមយ៉ាងភាពាប ។

ក្នុងរជ្ជសម័យនៃព្រះបាទយ៉ុង-ទី មានសេចក្តីចំរើនរុងរឿងក្នុងពេលដំបូង ។ តែគ្រាប់ចុះជាយថោកសាំសាយយ៉ាងចំឡែក ដោយហេតុ ២ ប្រការ គឺសេចក្តីសម្រេចផ្ទុយ ។ ១ របស់ព្រះបាទយ៉ុង-ទី បាន

ទៅផ្ទុតខ្លួចអស់ក្នុងរយៈពេលដែលកងប្រទេសកៅលី (ក្ងេ) គឺអាណាចក្រ
ផ្សេង ១ ទាងចុងបុញ្ជាប្រទេស ក្នុងរយៈនោះទៅសល់តែប្រទេសកៅលី
មួយទេ ដែលវាងងងឹតមិនត្រមមបំណុះព្រះអង្គ ទើបព្រះបាទយ៉ុង-ចំ ត្រូវ
ព្យាយាមលើកកងទ័ពយ៉ាងធំទៅកាន់ស្រុកនេះដល់ ២ លើកតែមិនសម្រេច
ហើយកងទ័ពរបស់ព្រះបាទយ៉ុង-ទី ក៏គ្រាន់ជួយខ្លួចខ្ជីអស់ពាន់ ២
ត្រា នេះជាប្រការ ១ ឯប្រការមួយទៀតនោះ គឺមកដល់ទាងចុងរជ្ជកាល
នេះ ព្រះបាទយ៉ុង-ទី ក្លាយទៅជាក្សត្រខ្សត់សតិសម្បជ្ញ: គាប់ចិត្ត
តែធ្វើការដែលនាំឲ្យបង់ទាតមាសប្រាក់ជាច្រើន ហើយបង្ហូរសេចក្តីលំបាក
គ្រាកយ៉ាកនឹងក្តៅក្រហាយ ដល់ប្រជាជនដោយឥតហេតុ ទៅទីបំផុត
ក៏ក្រឹតបះបោរបណ្ដាលលយ៉ាងខ្លាំងក្លា ពាជការក្សត្រស្រុកទេសក៏សាំ
សោយកាយមាស ពួកមេទ័ពមេកងដែលមានតួនាទីនៅកន្លែងដែលក៏ត្រាំ
រីងងងងឡើង មានពំនងដូចទាងដើមសម័យសាមកុក ទៅទីបំផុត
ព្រះបាទយ៉ុង-ទី គ្រាន់លះបង់ក្រុងលោ-យ៉ាងចេញទៅប្រថាប់នៅឯស្រុក
ក្ងៀង-ជូ ក្នុងឆ្នាំពុទ្ធសកាជ ១១៤៩ ។

ការដែលព្រះបាទយ៉ុង-ទី ស្ដេចរត់ចេញទៅដូច្នោះ គ្រាន់ប្រកាន់
ថាជាការលោចេញចាកពាជសម្ផត្តិដ្ឋ:ស្រឡះហើយ ក្នុងគ្រានេះឯង
ទើបពួកមេទ័ពនាយកងតាំងឡាយ សឹងមានបំណងចង់សោយពាជ្យ ទៅ
ឯកាសដែលពាជចល្ងង្ក:ពុងចំនេ ហើយក្នុងឆ្នាំពុទ្ធសកាជ ១១៥៥

(មានត)

រឿងកុមារពីរនាក់ជាមិត្តនឹងគ្នា

ព្រះគ្រូសិរីសោភ័ន កឹម-ទូ ក្រុមជំនុំព្រះត្រៃបិដក

(រៀបរៀងតាមនិទានចាស់)

ចៅស្រ៉ាហ៍ -

ខែរអើយយើងទាំងពីរនាក់ និយាយរួមរ័កអស់កាលវែង
ប៉ុណ្ណឹងហើយល្មមប្អូនពាក់តែង ទៅផ្ទះសម្បែងចាំទេវេលា ។
ព្រោះសុរិយាជិតអស្តង្គត ពន្លឺលេតក្នុងមេឃា
ឯប្អូននឹងបងតង់ជួបគ្នា ទឹងបានសន្ទនាគ្នាក្រោយអើយ ។

នាងវិរិយ៍ក៏លាចៅស្រ៉ាហ៍ទៅកាន់ផ្ទះអាត្មាវិញ អ្នកទាំង ២ មានចិត្តប្រតិព័ទ្ធគ្នាទៅវិញទៅមក ដល់កាលជាខាងក្រោយមក ចៅស្រ៉ាហ៍មិនមានភ្លេចអំពីនាងវិរិយ៍នោះឡើយ . បានពឹងពួកញាតិឲ្យចូលទៅដណ្ដឹង ឯម្ដាយនឹងពួកញាតិឯទៀតរបស់នាងវិរិយ៍ក៏ព្រមឲ្យដោយសេចក្ដីស្មោះស្ម័គ្រ ព្រោះស្រឡាញ់ចៅស្រ៉ាហ៍គ្រប់គ្នាដែរ ហើយក៏កំណត់ថ្ងៃខែនឹងរៀបធ្វើវិវាហមង្គល ។ ចៅស្រ៉ាហ៍បានឲ្យដំណឹងទៅចៅកុសជាសំឡាញ់ដែលនៅស្រុកក្រៅ អំពីពិធីរៀបមង្គលការ លុះដល់កំណត់ថ្ងៃហើយចៅកុសមកដល់ផ្ទះចៅស្រ៉ាហ៍ជាសំឡាញ់ ចៅស្រ៉ាហ៍ក្រឡេកឃើញចៅកុសស្លៀកពាក់មិនស្អាត មានទាំងបំណះខ្វះផង ចៅស្រ៉ាហ៍មានសេចក្ដីអៀនខ្មាសភ្ញៀវដែលមកជួបជុំក្នុងផ្ទះរោងពេក ក៏នាំចៅកុសចូលក្នុងបន្ទប់ឲ្យផ្លាស់ខោអាវចាស់ៗចោលចេញ ហើយឲ្យខោ

នឹងការមួយប្រដាប់មកទៅកុសស្លៀកពាក់ ចៅកុសជួបតាត់ថែងមង្គល-ការហើយស្រេច កន្លងទៅបានពីរបីថ្ងៃក៏លាទៅ ចៅ។ស្រហ៍ជាសំឡាញ់ថានឹងត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ៗ ចៅ។ស្រហ៍សួរចៅកុសថា យីអើសំ-ឡាញ់ ផ្ទះសំឡាញ់ឯងមានដំណាំសម្បូរដូចខ្ញុំដែរឬ? ចៅកុសថាផ្ទះខ្ញុំគ្មានអ្វីទេ ដោយខ្ញុំមិនបានដាំនឹងគេ ៗ

ចៅ។ស្រហ៍ថា បើដូច្នេះសំឡាញ់ឯងយកពូជខ្លះទៅដាំចុះ ហើយក៏ចាត់ថែងពូជមានគ្រាប់ខ្លះ កូនខ្លះឱ្យទៅចៅកុស ៗ បានហើយ ក៏វែកយកពូជទាំងនោះទៅកាន់ផ្ទះរបស់ខ្លួន លុះដល់ហើយក៏មិនរវៀសវៃនឹងដាំភ្លាម ទុកកន្លងទៅ ៣-៤ ថ្ងៃ កណ្ដុរកើស៊ីគ្រាប់ កូនឈើក៏ស្លោកស្លាប់ទៅដោយមិនបានស្រោចទឹក ចៅកុសក៏ខានដាំដំណាំតទៅទៀតដោយអំណាចសេចក្ដីខ្ជិលច្រអូសយ៉ាងនេះឯង ៗ

កុសអើយចៅកុស គិតតែបណ្ដោះ ភែខាងក្ដីខ្ជិល គេនៅជិតខាងកុសឥតមើល មានតែកំជិល យកជាត្រីមុខ ៗ វិជ្ជាចំណេះ គ្មានចាំគ្មានបេះ ល្បីខ្ចាពេញស្រុក ថាជាមនុស្សល្ងង់ គ្មានទ្រព្យសល់ទុកដេកព្រួយស្លុតមុខ ពលពេលវេលា ៗ គិតរកប្រពន្ធ គ្មានទីករះគន់ត្រង់ខ្លួនអាត្មា គេប្រកែកគ្រប់ ឥតសល់នរណា កើតបិត្តសាវ៉ា ពោះម៉ាយទល់ស្លាប់ ៗ

ចៅឧស្សាហ៍ការរួចហើយ កន្លងទៅបាន ១ ខែទឹកចង់ទៅលេងចៅកុសជាសំឡាញ់ឯស្រុកក្រៅ ក៏នាំនាងវិរិយ៍ជាប្រពន្ធទៅជាមួយដែរ លុះទៅដល់ផ្ទះចៅកុសហើយឃើញដីភូមិគ្មានដំណាំអ្វីសោះ មានសុទ្ធតែស្មៅនឹងឈើឥតប្រយោជន៍ដាសពាសពេញទាំងភូមិ ឯផ្ទះសោតទៀតក៏ធ្លុះធ្លាយទទ្រេតទទ្រោតស្មោកគ្រោកសព្វកន្លែង ឯចៅកុសក្រឡេកឃើញសំឡាញ់មកដល់ ក៏ញញឹមញញែមចុះទៅទទួលពក់ពាក់នាំសំឡាញ់ឡើងលើផ្ទះ ចៅឧស្សាហ៍នៅបាន ១ ថ្ងៃសួរថា នែសំឡាញ់ កាលសំឡាញ់ឯងទៅផ្ទះយើងៗ បានឲ្យពូជដំណាំគ្រប់យ៉ាងមកដាំ ម៉េចក៏មិនឃើញមានដំណាំអ្វីសោះ? ចៅកុសឆ្លើយថា អើសំឡាញ់. ភ្លាយគមកមិនទាន់បានដាំផង ស្រាប់តែកណ្ដុរស៊ីពូជទាំងកូនឈើក៏ងាប់អស់ទៅ រកទៀតមិនបានៗ ចៅឧស្សាហបានឮចៅកុស និយាយទំនាស់ដោយសេចក្ដីខ្ជិលដូច្នោះ ក៏ខំនិយាយរំឭកដាស់តឿនចៅកុសអំពីទោសនៃសេចក្ដីខ្ជិលប្រហូសថា នែសំឡាញ់យើងនៅទីក្រុងឧស្សាហ៍បានស្ដាប់លោកអ្នកប្រាជ្ញសំដែងពីទោសនៃសេចក្ដីខ្ជិលជាអនេកប្បរិយាយថា

ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ គ្រប់ជាតិគ្រប់សាសន៍សុទ្ធតែមានធម៌ជាគូៗ អាស្រ័យនឹងគ្នា ដូចយ៉ាងខ្ជិលជាគូនឹងឧស្សាហ៍ ល្ងង់ជាគូនឹងចេះ អាក្រក់ជាគូនឹងល្អ ក្រជាគូនឹងមានបាបជាគូនឹងបុណ្យ មានដូច្នេះជាដើមៗ

ក្នុងទីនេះនឹងអធិប្បាយតែអំពីសេចក្តីខ្ជិល ជាគូនឹងសេចក្តីព្យាយាមប៉ុណ្ណោះ ដើម្បីឲ្យឃើញទោសនឹងអានិសង្សនៃសេចក្តីខ្ជិលនឹងសេចក្តីស្វាហាប់ដោយឡែកពីគ្នា សេចក្តីខ្ជិលនេះ កាលបើពិចារណាដោយស្មើៗ ហាក់ដូចជាល្មក់ល្មម មិនជាឲ្យទោសប៉ុន្មាន តែបើប្រើគំនិតឲ្យជ្រៅទៅមិនមែនដូច្នោះទេឡើយ សេចក្តីខ្ជិលនេះជាមេក្រមិចនៃធម៌ ឬជាសឹកសត្រូវអាក្រក់បំផុត រមែងធ្វើមនុស្សឲ្យថោកមិនមានដំឡៃ សូម្បីព្រះពុទ្ធជាម្ចាស់ ក៏ទ្រង់ត្រះត្រិះរៀលសេចក្តីខ្ជិលជាអនេកដោយពុទ្ធភាសិតថា

អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំជាមន្ទិល សេចក្តីខ្ជិលជាមន្ទិលរបស់សម្បុរ សេចក្តីធ្វេសប្រហែសជាមន្ទិលរបស់បុគ្គលអ្នករក្សា (ទ្រព្យ) ។

សេចក្តីអធិប្បាយថា បណ្តាមន្តវិជ្ជាអ្វីទាំងអស់ក្នុងលោក ទោះវិជ្ជាជាលោកិយគឺអក្សរសាស្ត្រលេខនព្វន្តគុណហារជាដើមក្តី ឬវិជ្ជាជាលោកុត្តរ គឺធម៌វិន័យបរិយត្តិសាសនាជាដើមក្តី កាលបើសិក្សារៀនចេះចាំជំនាញស្ទាត់ប្រាកដហើយ តែខ្ជិលមិនបានព្យាយាមរំឭកបន្ថែមទេ ឬមិនបានយកចំណេះដែលខ្លួនរៀនចេះហើយនោះមកប្រកបប្រើការទេ ជាហេតុនាំឲ្យកើតទៅជាទោសគឺក្លាយសាបសូន្យបាត់បង់ទៅវិញប្រើការមិនកើត ។

ទីលំនៅដែលខ្លួនធ្លាប់នៅអាស្រ័យជាប្រក្រតី បណ្ដោយឲ្យស្មោកគ្រោក ដោយធូលីសំរាមសំបកកកកាយពាសពេញក្នុងផ្ទះ ទាំងសម្បុកពីងពាង ផែងរង្គើងរុំខ្ចៅព័ទ្ធពីលើពីក្រោម ស្រកេកស្រកាក់ក្នុងផ្ទះ ឬផ្ទះនោះលេចបាក់បែកធ្លាយធ្លុះទម្រុះទម្រោត មិនថែជួសជុលសំអាតទេ ជាហេតុនាំឲ្យទៅជាទោសគឺកើតអន្តរាយឬរោគផ្សេងៗ ដល់មនុស្សអ្នកនៅក្នុងផ្ទះមិនខាន ។

បុគ្គលជាគ្រហស្ថក្ដី បព្វជិតក្ដី ប្រកបដោយសេចក្ដីខ្ជិលច្រអូស កាលបើរាងកាយប្រឡាក់ប្រឡូសដោយមន្ទិលគឺធូលីក្អែលក្អក ឬញើសហូរពេញមកអាប់អួរធុំក្លិនអាក្រក់អសោចហើយ មិនបានលាងជម្រះដោយទឹកនឹងគ្រឿងលុបលាបទេ ជាហេតុនាំឲ្យមានសម្បុរអាក្រក់បណ្ដាលទៅជារោគផ្សេងៗ មានបូសបមកមរមោសជាដើមជាទីខ្ពើមរអើមដល់គេអ្នកនៅជិតខាង ពុំនោះសោត គ្រឿងស្លៀកពាក់ ប្រឡាក់ដោយញើសក្អែលធូលីអាប់អួរ មិនស្ងោរបោកគក់ជ្រលក់លាងហាលធ្វើឲ្យស្អាតបាតទេ ជាហេតុនាំឲ្យមានពណ៌អន់អាប់អាក្រក់ ធុំក្លិនអសោចដល់អ្នកដទៃ ឆាប់ចាស់ឆាប់ហែក នេះក៏ជាទោសមកអំពីសេចក្ដីខ្ជិលនោះឯង ។

បុគ្គលអ្នករក្សាទ្រព្យសម្បត្តិដែលមានវិញ្ញាណក្ដី អវិញ្ញាណក្ដី មានគោក្របីជាដើម ប្រកបដោយសេចក្ដីធ្វេសប្រហែស ខ្ជិលច្រអូស រវល់តែដេក ឬរវល់តែនឹងលេង បណ្ដោយឲ្យគោក្របីទាំងនោះរត់បាត់

ទៅឬអត្តពាយដោយម្រ៉ែតសាហាវពាប់ស៊ី នឹងចោរលួចជាដើម ប៉ើមិនដូច្នោះទេ គោត្រូវនោះឯងចូលទៅស៊ីដំណាំជាំផ្ទុះរបស់គេ ។ ក៏ចាប់យកទៅពិន័យលក់ជាសំណងបង់ទ្រព្យធនធានឬខ្លួនឯងក៏ដល់ខ្ទាប់ពិន័យទោសថែមទៀត ពុំនោះសោត គេដេរប្រមេបផ្សេង ។ ក៏មាន ម្យ៉ាងទៀតទ្រព្យសម្បត្តិសម្រាប់ប្រើប្រាស់ក្នុងផ្ទះមានមាសប្រាក់ជាដើម មិនបានរៀបចំពុកជាក់ បណ្តោយឲ្យកត់ពាយឥតសណ្តាប់ធ្នាប់ ម្ចាស់ហើយក៏នឹងដល់ខ្ទាប់សេចក្តីវិនាសអន្តរាយ មានចោរលួចជាដើម ពាក្យនេះ ក៏ជាហេតុមកតែអំពីមនុស្សគឺសេចក្តីធ្វេសប្រហែសឲ្យលហ្ន៏ងងង ។

ទៅ១ស្ស្ហ៍ទ០និយាយតទៅទៀតថា នែសំឡាញ់ ។ ឯងសង្កេតមើលចុះកូនស្រីតន្ទីមួយ ។ មនុស្សដែលមានគំនិតនឹងមនុស្សដែលឥតគំ-និតពុំសគ្នា មនុស្សដែលមានគំនិតនោះគឺដីកូមិជុំវិញផ្ទះគេជាំដំណាំផ្សេង ។ មានតាំងពីស្លឹកត្រៃគ្ងីមួសបន្ទ្ងសម្រាប់ធ្វើជាអាហារមានគ្រប់យ៉ាង រហូតដល់ដំណាំដើមធំ ។ មានខ្ទ្ងរត្រូចជូងជាដើមណែនពេញតាំងកូមិ គេមិនមែនទុតបណ្តោយឲ្យស្មៅនឹងរលៀងដុះពាសពេញក្នុងកូមិ ឥតប្រយោជន៍ដូចជាសំឡាញ់ឯងនេះទេ ។ ឯមនុស្សដែលឆ្ងៃឥតគំនិតនោះ កុំថាឡើយដល់ទៅដំណាំដើមធំ ។ មានបេតទៀបល្ងតជាដើម សូម្បីតែជីស្លឹកត្រៃគ្ងីមួសរំដេងរមៀតខ្លាយដែលជារបស់ត្រូវស៊ីកាលនៃ ក៏គ្មានគិតអើពើនឹងជាំដែរ រីឯត្រូវការគេមិនបានដើរកេសុំគេជ្រ៉ាយផ្ទះដ៏ត្ងាង ធ្វើបែបនេះ

ហៅថាមនុស្សថោក ម្យ៉ាងទៀតមនុស្សអ្នកមានគំនិតមានព្យាយាមនោះ របស់ណាដែលគេត្រូវប្រើគល់ថ្ងៃខានមិនបាន ដូចយ៉ាង ឧស ទឹក អង្ករជាដើម គេធ្វើតែម្តង ទុកប្រើបានយូរថ្ងៃ ឧសគេរកមកពុះគរ រៀបទុក ទឹកគេដងដាក់ពាងទុក អង្ករសោតទៀតគេធ្វើតែម្តងប្រើយូរថ្ងៃបាន ឯមនុស្សខ្ជិលឥតគំនិតមិនដូច្នោះទេ វេលាដល់ពេលចំអិនអាហារនឹងបរិភោគ ទើបបានទៅរកដងទឹកបុកអង្ករហើយដើររើសកាប់ឧសតាមក្បែរបេង ទំរាំបានបាយ ១ ឆ្នាំង សំឡ ១ ឆ្នាំង ទល់គ្នានឹងថ្ងៃត្រង់នាំឲ្យខាតពេលដែលនឹងត្រូវប្រកបការងារឯទៀតៗ ទៅអស់ បែបនេះហើយដែលនាំឲ្យទៅជាមនុស្សដុនដាបខ្សត់ខ្សោយកោតសម្បែ ព្រោះមិនចេះចាត់ការតាមកាល ។

នែសំឡាញ់ៗ ឯងស្តាប់បានឬទេ ? ចៅកុសឆ្លើយថា អើ ខ្ញុំស្តាប់បានហើយ ប៉ុន្តែខ្ញុំចង់សួរសំឡាញ់ឯងវិញថា តាមដែលខ្ញុំបានឮគេនិយាយថាមាននឹងក្រគឺមកពីសំណាងយើងពីនាយមក អីចឹងមែនឬទេ ? ចៅឧស្សាហ៍ថា ឱសំឡាញ់អើយ ! សំឡាញ់ឯងកុំទៅចូលចិត្តស៊ប់ដូច្នោះពេក ចំណេះវិជ្ជាក្តី ទ្រព្យសម្បត្តិក្តី មិនមែនកើតឡើងហើយស្រាប់តែចេះដឹងឯង មានទៅឯងនោះទេ គឺមកពីមានព្យាយាមខំរៀនខំរកទើបចេះទើបមានទៅកើត ដែលខ្ញុំនិយាយមកនេះ មិនមែនបដិសេធសំណាងនោះចោលទេ តែយើងមិនត្រូវលង់គំនិតនឹងសំណាងនោះឡើយ ដូចមាន

រឿងព្រេងដំណាលថា មានគ្រូម្នាក់ចេះវេទមន្តទាយលក្ខណៈ ឲ្យកុមារពីរនាក់ កុមារម្នាក់គ្រូនោះមើលលក្ខណៈហើយទាយថា អាអ្នកឯងគ្មានលក្ខណៈ ជាមនុស្សមានបុណ្យមានសំណាងទេ នឹងទៅជាមនុស្សអនាថាខ្សត់ខ្សោយសម្បត្តិ កុមារនោះបានឮគ្រូទាយលក្ខណៈខ្លួនដូច្នោះក៏មានសេចក្តីតក់ស្លុតភ័យនឹងក្រ ខំប្រឹងប្រែងប្រកបការងាររកស៊ីមិនខ្លាចនឿយហត់តាំងយប់តាំងថ្ងៃ សន្សំទ្រព្យទុកដាក់មិនយូរប៉ុន្មានក៏បានឡើងទៅជាសេដ្ឋីមានសម្បត្តិរាប់កោដិ ៗ ឯកុមារម្នាក់ទៀត គ្រូនោះទាយថា អាអ្នកឯងជាមនុស្សមានលក្ខណៈល្អសមជាអ្នកមានបុណ្យ អំណើះតទៅនឹងបានជាអ្នកមានទ្រព្យស្តុកស្តម្ភមាំមួន កុមារនោះបានឮគ្រូទាយលក្ខណៈឲ្យដូច្នោះ ក៏សប្បាយចិត្តលោតកញ្ឆេងកញ្ឆាត់ មិនគិតប្រកបកិច្ចការរកស៊ីដេករង់ចាំតែសំណាងមិនយូរប៉ុន្មានក៏ទៅជាក្រីក្រខ្សត់ខ្សោយ រកទីពឹងគ្មាន រស់នៅដោយសារទានរបស់អ្នកដទៃ. រឿងដែលខ្ញុំនិយាយមកនេះ សំឡាញ់ឯងស្តាប់បានឬទេ?

ម្យ៉ាងទៀត អម្បាលដូចយ៉ាងព្រះសម្ពុទ្ធព្រះអង្គជាអគ្គបុគ្គលប្រសើរបំផុតក្នុងលោក ទ្រង់កសាងបំពេញបារមីអស់ ៤ អសង្ខេយ្យ ១សែនកប្ប លុះដល់បច្ឆិមជាតិ មើចព្រះអង្គទ្រង់ចេញបព្វជ្ជា ខំធ្វើព្យាយាមស្វះស្វាធ៍ការនោបំពេញទុក្ករកិរិយានឿយហត់អស់ ៦ វស្សា ទើបបានត្រាស់ដឹងជាព្រះពុទ្ធទៅបាន ៗ នែសំឡាញ់ ចំណេះវិជ្ជាក្តី ទ្រព្យសម្បត្តិក្តី

ឬគុណវិសេសឯណានីមួយក្តី មិនមែនបានមកដោយងាយ ៗ ឡើយ លុះតែខំប្រឹងខំព្យាយាមមិនខ្លាចដល់ការនឿយហត់លំបាក ទើបសម្រេចប្រយោជន៍ទៅបាន សមដូចសុភាសិតអ្នកប្រាជ្ញលោកសំដែងទុកមកថា

ខ្ជិលនឹងបានតម្រិះមកអំពីឯណា គ្មានតម្រិះហើយនឹងបានទ្រព្យមកអំពីឯណា គ្មានទ្រព្យហើយនឹងបានមិត្រមកអំពីឯណា គ្មានមិត្រហើយនឹងបានសុខមកអំពីឯណា គ្មានសុខហើយនឹងបានបុណ្យមកអំពីឯណា គ្មានបុណ្យហើយនឹងបានសួគ៌និព្វានមកអំពីឯណា ។

ចៅទសព្រហ៍និយាយដាស់តឿនចៅកុស អំពីទោសនៃសេចក្តីខ្ជិលដោយន័យជាអនេកយ៉ាងនេះ ។ ចៅកុសស្តាប់បានហើយក៏លាន់មាត់ដោយស្តាយខ្លួនថា ឱ! សំឡាញ់មែនហើយ ខ្ញុំបានជាធ្លោយគំនិតតាស់ខុសជាប្រាកដ កាលពីដើមម្តាយឪពុកនាំខ្ញុំទៅនៅវត្ត មិនបានប៉ុន្មានថ្ងៃក៏រត់មកនៅផ្ទះវិញ រហូតទៅនៅរៀនក្នុងសាលាជាមួយនឹងសំឡាញ់ឯងទៀតនៅតែមិនចេះ ទល់មកសព្វថ្ងៃនេះ ដោយសេចក្តីខ្ជិលរបស់ខ្ញុំជាប្រាកដ ។ ចៅទសព្រហ៍បានឮសំឡាញ់និយាយត្អូញត្អែរស្តាយខ្លួនដូច្នោះ ក៏ដំណាលរឿងខ្លួនប្រាប់ចៅកុសសព្វគ្រប់ ។

ចៅកុសបានស្តាប់ចៅទសព្រហ៍និយាយពីទោសនៃសេចក្តីខ្ជិល ក៏ឆ្លើយអែបតែខាងខ្ជិលថា នែសំឡាញ់អើយ? មនុស្សក្នុងលោកដូចជាដូចមិនមែនជាជាងគ្នាប៉ុន្មានៈ បើទុកជាឯងចេះដឹងមានប្រាជ្ញាយ៉ាងណាក្តី

មានសម្បត្តិច្រើនយ៉ាងណាក្តី មានគ្រឿងស្លៀកពាក់ល្អយ៉ាងណាក្តី បរិ-ភោគល្អយ៉ាងណាក្តី ក៏មិនឃើញវិសេសទៅឯណាដែរ, គង់តែស៊ី ១ ឆ្អែត ស្លៀក ១ ចង្កេះ ដេក ១ ដំណេកប៉ុនគ្នា ។ ចៅឧស្សាហ៍-ឧសំឡាញ់ៗ ឯងយល់នោះមែនដែរហើយ ប៉ុន្តែបើតាមសេចក្តីពិតនោះមិនមែនដូចសំឡាញ់ឯងថានោះទេ ប្រសិនបើដូច្នោះមែន មនុស្សក្នុងលោក គ្មានចេះ គ្មានល្ងង់ គ្មានមាន គ្មានក្រ គ្មានល្អ គ្មានអាក្រក់ទេ មនុស្សណាមួយ មានគំនិតយល់ដូចជាសំឡាញ់ឯងនេះ មិនមែនហៅថាជាអ្នកមានគំនិតមានព្យាយាមល្អនោះទេ ចាត់ថាជាមនុស្សទំម្រន់ខ្ជិលទេតើ សមដូចពាក្យបុរាណថា ដេកផ្សំផ្តួល រមួលផ្សំគ្រប គំនិតទាំងសំដីមនុស្សបែបនេះ នឹងយកជាការពុំបានឡើយ ។

ចៅឧស្សាហ៍ បាននិយាយរំឭកដាស់តឿនចៅកុសអំពីទោសនៃសេចក្តីខ្ជិលនឹងអានិសង្សនៃសេចក្តីព្យាយាមសព្វគ្រប់ហើយ ក៏លាចៅកុសជាសំឡាញ់នាំនាងវិរិយ៍ជាប្រពន្ធ ត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួនវិញ; ចៅឧស្សាហ៍នឹងនាងវិរិយ៍ថែទាំដំណាំនឹងប្រកបការជំនួញផ្សេងៗ សន្សំទ្រព្យទុកដាក់ ក៏បានទៅជាអ្នកមានសម្បត្តិស្តុកស្តម្ភ មានកេរ្តិ៍ឈ្មោះផ្សាយខ្ចរទៅថាជាមនុស្សមានគំនិត មានព្យាយាមល្អ ។

អ្នកទាំងពីរក៏នៅរួមគ្នា ប្រកបដោយសេចក្តីសុខអស់មួយជីវិតរៀងខ្លួនទៅហោង ។

១ស្សហ៍អើយ១ស្សហ៍ ល្ងីល្ងើសាយសុស ពីព្រោះព្យាយាម
តាំងពីដើមក្តី ឃ្មាតខ្ចីរៀនភ្ជាម គ្មានគិតរមែងម
ន់ធ្ងន់ការលេងលេង ។ មានចិត្តសង្ហាត ថ្ងៃតាំងអាត ទ្រព្យផងផ្សេង ១ តាំងថ្ងៃដណ្ដាំ គ្មាន
ទីតការលេង ព្រោះចិត្តគិតលេង យល់ផ្លូវប្រយោជន៍ ។ សន្សំទ្រព្យ
ទុក ការពារ១ម្ដុ១ ខ្ជាចត្រែងហ៊ានហោច ១ាល់ត្រលំបាក ១ើត
ទុក្ខត្រមោច ត្រូវឲ្យអាណោច អាធម្មាលីសលន់ ។ លុះអាយុ ២០
មានចិត្តមមៃ គិតរកប្រពន្ធ ចានពីងពួកញាតិ ឲ្យជួយគិតគន់ ១ាយ
ឯយទ្រព្យធន រៀបមង្គលការ ។ លុះការរួចហើយ ១ស្សហ៍ពុំកន្ដើយ
ទីតដល់ស្នេហា ១ុសជាសំឡាញ់ ១ៅស្រុកចំការ មានតំស្ពុ១ឡារ
យ១ាតៅផ្ទៃផង ។ ១ាលៅ១ាដល់ផ្ទះ ឃើញ១ាលស្រឡះ ១ាតមានបេង
ដំណាំផ្សេង ១ ១ាតមានមួយ១ង ឃើញ១ុសដេ១ាង ១ាតីខ្ទុ១ម្ចាក់ឯង ។
១ស្សហ៍ប្រដៅ១ា ១ាមព្រះទេសនា មនុស្ស១ិលតណ្ណ ១ៅ១ា
មនុស្ស១ាត់ ១ាតគេ១ាតត្រែង ព្ងាយចិត្ត១ាណ្ណ ១ាងគេ១ាកប់ ។
ធម្ម១ាមនុស្ស១ិល ១ាងគិតរមិល ត្រង់ការ១ាកទ្រព្យ លុះស្ងួតធ្ងាំ
ចាយ ១ើបផ្ទាយដើងញ្ជាប់ ១ីតមុ១ស្រ១ាប់ ១ាកខ្ជីញ្ជាតិមិត្ត ។
ចប់ពាក្យប្រដៅ ១ស្សហ៍ថានៃ១ៅ ១ុសអើយគួរគិត ១ាំចូ១ការ១ាត្ត
១ុំស្ពាយដ៏ដ្ឋ ត្រូវ១ាតពិនិ១ស ១ើ១ុ១ប្ដ
ន ។ ១ ១ួចស្រ១ាលណា
១ស្សហ៍និយាយលា ១ាំ១ាងប្រពន្ធ សំដៅ១ៅផ្ទះ ១ូ១ារ១ាតគន់

កិច្ចការប្រែនលន់ នៅផ្ទះអាត្មា ។ កាលដល់ផ្ទះហើយ ។ ស្រហ៍ពុំស្ងៀម ទៀយ ធ្វើការនានា ដោយក្តីខ្វះខ្វំ សន្សំគោគា បានប្រែនជាគ្នា ការពារប្រាណហោង ។

អធិប្បាយសុភាសិតខ្មែរ

យុនឡុមប្រឹជា បាប-ពិន

រៀបរៀង (តមក)

៥៧ - ចេះប្រើនពេករបេះក្បាច់

ពាក្យនេះជាពាក្យពោលបណ្តោយ

ចែបជាបញ្ជោះទៅតាមគ្រាយ គឺពាក្យថាឲ្យអ្នកធ្វើអ្វី ។
ដោយចិត្តព្រហើនឬប្រញាប់ ឲ្យភ្លាត់ចំណាប់ខុសប្រកតី
មានដើមថាក្មេងប្រុសឬស្រី ចបេសធ្វើអ្វីរបស់បាស់ ។
ដែលគេទុកទើរលើទីណា ខ្លួនយកហត្ថាកាន់លេងផ្តាស
កាលខូចតែងត្រូវពួកមនុស្សបាស់ ស្តីឲ្យរហ័សដូចមាតិកា ។
ថា "ចេះប្រើនពេករបេះក្បាច់" ក្រឡាច់ខូចខាតនាំសាវ៉
ហេតុនេះបុរាណគេបពោលថា ដាស់តឿនបញ្ញាជនជាន់ក្រោយ ។

៥៨ - ចេះឯង ឲ្យគ្រោងចេះគេ

សុភាសិតនេះប្រាជ្ញទូន្មាន

មិនឲ្យអ្នកចេះធ្វើឈ្ងានពាន ទន្ទ្រានរំលោភលើអ្នកផង ។
ទោះបីខ្លួនចេះចំណេះណា ត្រូវបើកនេត្រាមើលទំនង
ចំណេះនៃគេឯទៀតផង កុំបីរំលងរំលោភពេក ។
ត្រូវតិតថាសរពើចំណេះ មិនចេះតែឯងពាសពេញមេយ
ឆងមានគេចេះជាអនេក ចម្រៃកជាងខ្លួនរាប់មិនបាន ។

មួយទៀតអ្នករៀនចំណេះអ្វី ត្រូវខំឃ្មាតខ្មីឲ្យបំណាន
ទោះចេះចំណាប់ក៏កុំស្មាន ថាខ្លួនឯងបានចេះម្ចាត់ឯង ។
ត្រូវគិតថាមានគេចេះទៀត ខំខ្ចៀតគេរៀនដោយគិតក្រែង
ខ្លាចគេបានចេះច្រើនលើសឯង ប្រឹងប្រែងរៀនទៀតទើបបានល្អ ។

៥៩- ចោលសាច់ស្រក់ឆ្អឹង, ទំពាទៅរឹង

ទើបជាការកាសាច់

ពាក្យនេះលោកពោលជាប្រស្នា
ឲ្យយើងទាំងឡាយស្ដាប់ពល់គ្នា ព្រះហើយកាលណាខំប្រឹងគិត ។
ពាក្យថា "ចោលសាច់ស្រក់ឆ្អឹង" បើនឹងអធិប្បាយឲ្យឃើញពិត
បានខាងអ្នកណាមិនសូវគិត ចោលញាតិជិតៗ របស់ខ្លួន ។
ទៅគប់នឹងមនុស្សមិនមែនញាតិ ខំឃ្មាតផ្គាប់ផ្គុនគេម៉ាមួន
ស្រឡាញ់យ៉ាងស្និទ្ធក្បែរគិតខ្លួន រុកគួនពួកញាតិរបស់ឯង ។
ធម្មតាមិនមែនជាបងប្អូន ល្អុះល្អួនមិនបានយូរអង្វែង
បើកើតអាក់អន់ក៏រមែង លះលែងស្រឡាញ់ឈប់គប់អាខ ។
កាលៈបើដូច្នោះទើបត្រឡប់ មកគប់ប្រសព្វសាច់សន្ដាន
ហេតុនេះអ្នកប្រាជ្ញពីបុរាណ លោកបានចងជាសុភាសិត ។
ថា "ចោលឯសាច់ស្រក់ឆ្អឹង ទំពាទៅរឹងទើបបានគិត
ឆាកមករកសាច់ខ្លួនឯងពិត" ដោយទាល់គំនិតគេបំរើ ។

៦០- ចៅហ្វាយឡើងបុណ្យ, ខ្ញុំឡើងស័ក្តិ;
ចៅហ្វាយអប្បលក្ខណ៍, ខ្ញុំធ្លាក់ឥតឫង

ពាក្យនេះហោភណលោកអភិប្រាយ

ពីមនុស្សដែលជានាយចៅហ្វាយ រមែងខ្វល់ខ្វាយយ៉ាងមាំមួន ។
ដល់ខ្ញុំអ្នកនៅក្រោមបង្គាប់ ដែលធ្លាប់ទំនុកបម្រុងខ្លួន
ឲ្យសុខសប្បាយពេញសំនួន តាមភាពដែលខ្លួនគួរធ្វើបាន ។
ហេតុនេះអ្នកនៅក្រោមបង្គាប់ មានកំពូងដោយសារនាយថ្កើងថ្កាន
បើនាយឡើងស័ក្តិខ្ញុំក៏បាន សុខសាន្តដោយបុណ្យនាយចៅហ្វាយ ។
បើនាយខូចយសជាអប្បលក្ខណ៍ ពួកខ្ញុំក៏ធ្លាក់ខូចខាតខ្លាយ
នេះជាធម្មតាខ្ញុំនិងនាយ ដូចអធិប្បាយមកនេះឯង ។

៦១- ចំណីល្អកុំអាលស៊ី

សុភាសិតនេះលោកទូន្មាន

ឲ្យយើងចេះអត់សេចក្តីឃ្លាន ដែលមានក្នុងចិត្តជាធម្មតា ។
ពាក្យថា "ចំណីល្អចំណាប់" ដែលប្រាជ្ញពោលប្រាប់ក្នុងនាតិកា
បានដល់វត្ថុផ្សេងនានា សឹងជាគម្រែករបស់ចិត្ត ។
មានមាសនិងប្រាក់ជាដើមនិង ដែលមានអ្នកឯងជាញាតិមិត្ត
គេសូកអន្ទងឲ្យជួយគិត ប្រឌិតកិច្ចការផងទាំងឡាយ ។

ត្រូវគិតពិនិត្យឲ្យជ្រាលជ្រៅ ដោយនូវកិច្ចកលនយោបាយ
បើយើញថាល្អមិនអន្តរាយ សឹមជួយទូល់ទូយឲ្យត្រប់ត្រាន់ ។
បើយើញមិនស្រួលកុំបរិភោត ក្រែងស្ទោកជល់ទូនកើតទោសទណ្ឌ
ហេតុនេះបុរាណពោលបន្មន់ កុំឲ្យយើងភាន់ស៊ីភ្ជាមឡើយ ។

៦៧- ចំណីល្អកុំទុកស្អែក, ប្រពន្ធតាប់ក្នែក
កុំឲ្យដើរក្រាយ

ពាក្យនេះលោកពោលដោយមធ្យ៉ត

ឲ្យយើងបេះប្រុងបេះប្រយ័ត្ន បេះជុសបេះទាត់បេះសង្ទាត ។
ឯចំណីល្អកុំទុកស្អែក ជូចការបម្ចែកយ៉ាងល្អស្អាត
មានជលប្រយោជន៍មិនទូចទាត ត្បូរកុំប្រមាទទុកយូរឡើយ ។
បើជឹងត្រូវធ្វើកុំបន្មន់ ភ្ជាម ៗ កុំរង់កុំកន្ពើយ
ប្រញាប់ចុះដៃធ្វើឲ្យហើយ កុំរាវរកឡើយក្រែងសៅហ្មង ។
រីឯប្រពន្ធយ៉ាងល្អឯក តាប់ក្នែកទូនឯងនឹងអ្នកជង
អ្នកជាស្ទាមីត្រូវយុំត្រង កុំបីរំលងការរក្សា ។
ត្រូវឲ្យដើរមុទកុំទុកក្រោយ តឹកុំបណ្តោយឲ្យសាវ៉ា
ដើរហើរផ្តសផ្តាសតាមចិន្ត ឥតអារក្ខាមិនជាឡើយ ។

វណ្ណកតី

រឿងនារាយណ៍ទសាវតារ

ឧកញ៉ាទេពពិទូរ ក្រសេម រៀបរៀង

(តមក)

នរសិង្ហាវតារ (ក្នុងច្បាប់ហោព្រះសមុតកប់ជាគ្រាទី ៧) គ្រានេះព្រះនារាយណ៍បែងភាគជានរសិង្ហ កម្រាបហិរណ្យកសិបុជាប្អូនក្មេះរបស់ហិរណ្យាក្សៈ, ហិរណ្យកសិបុ មានចិត្តក្រេវក្រោធគុំគួននឹងព្រះនារាយណ៍ ទើបឧស្សាហ៍បំពេញតបៈពូជា ដើម្បីឲ្យព្រះព្រហ្មប្រទានពរ ព្រះព្រហ្មក៏ប្រទានពរតាមពាក្យសុំថា កុំឲ្យទេវតាមនុស្សរហូតដល់តិរច្ឆានសម្លាប់បាន នឹងកុំឲ្យស្លាប់ដោយអាវុធយ៉ាងណាៗ កុំឲ្យស្លាប់ក្នុងវេលាថ្ងៃកុំឲ្យស្លាប់ក្នុងវេលាយប់ កុំឲ្យស្លាប់ក្នុងផ្ទះ កុំឲ្យស្លាប់ក្រៅផ្ទះ កាលបានពរដូចប្រាថ្នាហើយ ក៏សំដែងឫទ្ធិតេជះដោយបំណងនឹងគ្រប់គ្រងត្រៃលោក លើកទ័ពទៅរុករានឋានព្រះឥន្ទ្រៗតស៊ូមិនបានក៏រត់ទៅ ទៃត្យៈក៏តាំងខ្លួនជាស្ដេចទេវតា បានសេចក្ដីក្ដៅក្រហាយយ៉ាងសាហ័ស, ព្រះឥន្ទ្រទើបទៅសូមឲ្យព្រះព្រហ្មជួយ ព្រះព្រហ្មណែនាំឲ្យសូមឫទ្ធិព្រះហរិៗ ប្រាប់ឧបាយថាឲ្យធ្វើជាខ្លាចទៅសិនទៅ ។

ហិរណ្យកសិបុ មានកូនឈ្មោះប្រហលាទជាអ្នកចិត្តបុណ្យ ចិត្តធម៌ គោរពរាប់អានខ្ជាប់ក្នុងព្រះហរិ បិតាទើបយកទៅឲ្យឫសីប្រដៅពត់និស្ស័យឲ្យលើកលែងគោរពព្រះវិស្ណុ តែប្រហលាទមានចិត្តជឿស៊ប់

ណាស់ទៅហើយ ប្រែមិនកើត ៗ នាថ្ងៃ ១ ប្រហ្លាទបានមកគាល់បិតាទូលថា មានចិត្តសទ្ធាខ្ជាប់ក្នុងព្រះនារាយណ៍ ហិរណ្យកសិបុក្រោធកេរៀងថា ប្រហ្លាទមើលងាយខ្លួន ថែមទាំងឫសីនោះទៅសរសើរព្រះវិស្ណុថា ប្រសើរលើសលែងអ្នកទាំងអស់ក្នុងត្រៃលោក អាចប្រទានពរដូចម្តេចក៏បាន ស្តេចយក្សក្រោធខ្លាំងណាស់ ទើបកំហែងឲ្យដកពាក្យ បើមិនព្រមដូច្នេះ ទឹងសម្លាប់បង់ ឫសីខ្ជាប់ក្រែងមានក្តីអន្តរាយដល់ខ្លួន ក៏អនុលោមតាម ទទួលយកប្រហ្លាទទៅប្រដៅកែខ្លួនជាថ្មី តមកថ្ងៃមួយបានចូលមកគាល់បិតាទៀត បិតាឲ្យសូត្រធម៌ស្តាប់លេង កុមារនោះនៅតែមានសទ្ធាខ្ជាប់ក្នុងព្រះវិស្ណុ ទើបយកវិស្ណុមន្ត[1] ឡើងសូត្រមុន បិតាពិរោធស្រែកសន្ធាប់ ហើយឲ្យពួកអាមាត្យនាំយកនាគមកឲ្យខាំបុត្រ តែអស្ចារ្យណាស់កុមារនោះអង្គុយព្រងើយ នាគខាំដូចម្តេចក៏មិនស្លាប់ ទើបឲ្យយកដំរីពុះប្រេងមកឲ្យព្រួច ដំរីជាន់ទឹងបាក់ទាល់តែភ្លុកទាលរលំក៏មិនស្លាប់, ទើបឲ្យយកទៅដុតក្នុងភ្លើង ៗ ឆេះសន្ធោរឡើង តែឥតក្តៅដល់កាយកុមារនោះឡើយ ៗ

ព្រាហ្មណ៍ចាស់បានសុំយកទៅប្រដៅទៀត តែក៏មិនសម្រេច បិតាទើបឲ្យយកថ្នាំពិសមកឲ្យលេបក៏មិនស្លាប់, ព្រាហ្មណ៍អាចារ្យទើប

---

១ មន្តនេះគាថាចំណៀម នៅស្រុកសៀមព្រាហ្មណ៍ព្រឹទ្ធាចារ្យបានសូត្រថ្វាយស្តេចក្នុងវេលា ឡើងព្រះទេពភ្ញៀវចិញ្ចឹមក្នុងវេលារាជាភិសេក ក្នុងវេលាក ម្តេចព្រះរាជបន្ទូរជាដើម ៗ

ទិរមិត្រជាស្រីមានខ្លួនជាក្មេងនៅទុះគុមារ ៗ ក៏មិនឈឺមិនស្លាប់ តែវេលា ឆាក់មកខាងព្រាហ្មណ៍ ៗ គេចមិនទាន់ ត្រូវក្មេងពេលខ្លួនឯងវិញ ប្រហ្លាទអាណិតអាចារ្យ ទើបសូមបារមីព្រះវិស្ណុកុំឲ្យអាចារ្យស្លាប់, បិតាៈទើបឲ្យហៅទៅសួរថា ហេតុអ្វីក៏បានជាដូច្នេះ ប្រហ្លាទទូលថា ព្រោះពឹងអាងព្រះវិស្ណុ ទើបបណ្តាលមិនឲ្យមានក្តីអន្តរាយ, ហិរណ្យក-សិបុ រឹតតែខឹងខ្លាំងឡើង ទើបឲ្យសេនានាំយកកូនទៅប្រានទម្លាក់អំពី កំពូលភ្នំ ដែលមានកំពស់ជាច្រើនយោជន៍ ប្រហ្លាទក៏ឥតមានរលាត់ ស្បែកដល់បន្តិច, បិតាទាល់គំនិត គឺឲ្យអាចារ្យយកទៅប្រដៅទៀត, តមកប្រហ្លាទត្រឡប់ជាណែនាំបិតាឲ្យកាន់តាមគោលធម៌គឺឲ្យជឿគោ-រពព្រះវិស្ណុ ហិរណ្យកសិបុក៏រឹតតែក្រោធណាស់ទៅទៀត អ្នកខ្លួនជា អាចកម្រោជបានតាំងតែកត ហើយបង្គាប់ឲ្យពួកទៃត្យៈចាប់កូនពងយក ទៅបោះចោលក្នុងទឹក ឲ្យយកដុំថ្មម្នាក់សង្កត់ថែមទៀត ដោយបំណង នឹងឲ្យស្លាប់ ប្រហ្លាទក៏ពយវិស្ណុមន្ត ហើយរលាស់របូតអំពីចំណង ទើបឡើងមកអំពីគំនរថ្មក្រាបបិតា សំដែងសេចក្តីយល់ឃើញថា ទូទៅ ក្នុងសាកលចក្រវាឡ អ្នកដែលប្រសព្វសុខប្រាសចាកទុក្ខនោះ ក៏ព្រោះ សេចក្តីករុណានៃព្រះវិស្ណុ ៗ ព្រះហិរណ្យកសិបុសំដែងទំនាស់ថា មិនមែន ជាមានឫទ្ធានុភាពដល់ម្ល៉ោះទេ, ប្រហ្លាទតដែកថា ព្រះវិស្ណុនោះស្ថិត នៅគ្រប់អន្ទើ អាចនឹងបណ្តាលជាអ្វី ១ បាន ១ រំពេច សូម្បីក្នុងខ្លួន

បំពាំងឯងថ្មក្នុងសសរក៏បាន ហិរណ្យកសិបុទើបចំអកឲ្យថា ហើ! ម្ល៉ោះឬ ព្រះវិស្ណុស្ថិតនៅក្នុងសសរ យើងសម្លាប់មិនស្លាប់ ថាតែប៉ុណ្ណោះ ក៏យកដំបងវាត់សសរបាក់រលំគ្រែងទៅ លំដាប់នោះក៏ឃើញនរសិង្ហដែលព្រះនារាយណ៍អវតារមក លេចចេញអំពីសសរមកចាប់ហិរណ្យកសិបុអូសទៅឯធរណីទ្វារសួរថា នេះជាមនុស្សឬសត្វ? ហិរណ្យកសិបុតបថា មិនមែនមនុស្សមិនមែនសត្វ, សួរថា នេះជាអាវុធឬអ្វី? តបថា មិនមែនអាវុធ នេះគឺក្រចក, សួរថាជាវេលាអ្វី? តបថា ជាវេលារវាងថ្ងៃនឹងយប់, នៅខាងក្នុងឬខាងក្រៅផ្ទះ? តបថា នៅរវាងពាក់កណ្ដាលមាត់ទ្វារ ។ កាលនរសិង្ហសួរដូច្នេះ ហិរណ្យកសិបុដឹងខ្លួនក៏ថា ព្រះអង្គនេះមានឫទ្ធិលើសលែងទេវតា នូវមនុស្សទាំងឡាយ, ព្រះអវតារ ទើបចាប់ហែកទ្រូងហិរណ្យកសិបុហើយក៏ក្លាយភេទជាព្រះនារាយណ៍ ព្រះហស្តបួនស្ដេចត្រឡប់ទៅកាន់វៃកុណ្ឋវិញដូចដើម ពួកទេពទិករក៏បានសុខដូចអំពីដើម ។

ច្បាប់ហោព្រះសមុទ្រពោលថា ហិរណ្យកអសុរចង់ជាធំក្នុងត្រៃភព ទើបបំពេញតបៈវិធីនៅជើងភ្នំព្រះសុមេរុ ១០០ ឆ្នាំ ព្រះជាម្ចាស់ក៏នៅមិនទាន់ប្រសិទ្ធពរឲ្យ អសុរទើបធ្វើបង្អើរផ្អើរខ្លួនទាល់តែខ្លាញ់ការស្រក់ចេញ ត្រងយកទៅអុជប្រទីបបូជាព្រះជាម្ចាស់ទាំងបី ៗ ក៏ស្ដេចមក ព្រះឥសូរប្រទានពរ, ព្រះនារាយណ៍ប្រទានគទា (ដំបង) ព្រះព្រហ្មគ្មានប្រទានអ្វីសោះ (ច្បាប់ពម ៦ នោះថាព្រះព្រហ្មតែមួយអង្គឯង) ហើយគិតតាំង

ខ្លួនផ្ទុំមទឹងព្រះនារាយណ៍ បានបង្គាប់ឲ្យឫសីសូត្រមន្តថា "ឱំ នមោ ធិច្ច មម" ចំនួសថា "ឱំ នមោ នារាយណា មម "ទេវតា ទើបទៅទូលព្រះឥសូរ ។ មានទេវឱង្ការឲ្យព្រះនារាយណ៍ បែងភាគមកក្រោម ព្រះនារាយណ៍បានឲ្យមហាសង្ខមកកើតជាបុត្រហិរណ្យកអសុរ នាមថាធម៌កុមារ, សេចក្តីក្រៅអំពីនេះប្រហែលគ្នា ។

រាមនាវតារតាមគម្ពីរភាគវតបុរាណៈ ពោលថា កាលគ្រាកូរទឹក ថ្នាំអម្ឫត អសុរបាញ់កលទេវតា មិនបានដកទឹកអម្ឫត វេលាច្បាំងគ្នា អសុរទើបជាអ្នកបាលបាញ់ជាដរាប ក្រុងពលីជាចៅប្រហោទបានគប់ គិតទឹងអសុរដទៃៗ ទៅកន្ទុះព្រាហ្មណ៍ ឫសីឲ្យជួបជីវិតពួកខ្លួនមកវិញដូចដើម ហើយលើកទ័ពទៅរុករានឋានព្រះឥន្ទ្រា ព្រះវជ្រីទើបសុំឲ្យព្រះព្រហស្បតិ៍ជួយ តែត្រឡប់ជាបានទទួលសេចក្តីណែនាំឲ្យទៅចំណុះព្រះវិស្ណុ ពួកទេពទ័ករនាំគ្នារត់ចេញអំពីបុរី អសុរយកបុរីបាន ក្រុងពលីក៏តាំងខ្លួនជាព្រះរាជាគ្រប់គ្រងត្រៃភព ។

ព្រះសក្កទេវរាជ ទឹងពួកទេពទិករទៅគាល់ព្រះកស្សបមុនីដ៏ជាប្រ-ជាបតីទឹងនាងអទិតិ វិសុទ្ធិទេពមាតា ព្រះប្រជាបតី ទើបឲ្យព្រះទេវីសូត្រសំបូងសម្រួងដល់ព្រះវិស្ណុ ១ ឆ្នាំមិនបាន ក៏អវតារចុះមកកើតជាឱរសរបស់ព្រះនាងនាមថា វាមនៈ (មនុស្សតឿ) តែមានប្រាជ្ញាស្រួច

(មានត)

ភណ្ឌុតិណ្ឌុកជាតក

តឹសតិនិបាត សត្តមភាគ

ព្រះបាឡាត់ពោធិកម យូរ-ប៉ុណ្ណ ក្រុមជំនុំប្រែព្រះត្រៃបិដក

ប្រែរៀបរៀង

កាលព្រះសាស្ដាគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវរាជោវាទហើយ ត្រាស់សំដែងធម្មទេសនាថា អប្បមាណោ អមគំ បទំ ផ្លុះប្រុះជាដើម ៗ

— មានសេចក្ដីដំណាលថា ថ្ងៃ ១ ព្រះរាជាកោសលទ្រង់បានវិនិច្ឆ័យនូវហេតុដែលកើតឡើងក្នុងដែនរបស់ព្រះអង្គ ដែលគេវិនិច្ឆ័យមិនត្រូវតាមច្បាប់ ប្រកបដោយអគតិ ឲ្យបានត្រឹមត្រូវតាមធម៌; រួចហើយព្រះអង្គទ្រង់ព្រះតំរិះបង់ទៅក្រាបបង្គំទូលដំណើរនោះ ចំពោះព្រះមានព្រះភាគ, លុះដល់ពេលសោយព្រះក្រយាស្ងាយរួច ស្ដេចឡើងគង់លើព្រះទីនាំងរាជរថទាំងថ្ងៃត្រង់ ទៅគាល់ព្រះមានព្រះភាគ ក្រាបថ្វាយបង្គំទៀបព្រះបាទាហើយគង់ក្នុងទីដ៏សមគួរ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា បពិត្រមហារាជ ស្ដេចយាងមកទាំងថ្ងៃត្រង់ តើមានការដូចម្ដេច? ព្រះរាជាកោសលក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ថ្ងៃនេះខ្ញុំព្រះអង្គបានវិនិច្ឆ័យនូវហេតុដែលកើតឡើងក្នុងដែន ដែលគេវិនិច្ឆ័យមិនត្រឹមត្រូវតាមច្បាប់ ប្រកបដោយអគតិ ឲ្យបានត្រឹមត្រូវតាមធម៌; ខ្ញុំព្រះអង្គមិនមានពេល

ឯណា ក្រៅពីពេលនេះ មកទូលសួរអំពីរឿងនោះចំពោះព្រះអង្គឡើយ ព្រោះខ្ញុំព្រះអង្គមានកិច្ចការច្រើន បានជាមកតាំងថ្ងៃត្រង់ សូមទ្រង់ព្រះមេត្តាប្រោសអត់ទោសឲ្យបាន ។

ព្រះសាស្តាទ្រង់ត្រាស់ថា បពិត្រមហារាជ ឯការវិនិច្ឆ័យដែលមហារាជកាត់សេចក្តីប្រកបដោយធម៌នេះក៏ជាកុសលជាដំណើរទៅកាន់សុគតិប្រាកដ; តែឯការវិនិច្ឆ័យនេះ មហារាជបានមកទទួលយកទុក្ខអំពីសំណាក់តថាគតដែលបានត្រាស់ដឹងហើយយកទៅវិនិច្ឆ័យដោយធម៌នោះ មិនមែនជាការអស្ចារ្យទេ ; កាលពីព្រេងនាយមានមហាក្សត្រដែលបានទ្រង់ព្រះសណ្តាប់នូវទុក្ខនៃអ្នកប្រាជ្ញទាំងឡាយ ដែលមិនទាន់បានត្រាស់ដឹងដូចជាតថាគតនៅឡើយ ហើយយកទៅវិនិច្ឆ័យនូវហេតុដែលកើតឡើងក្នុងដែនឲ្យប្រកបដោយធម៌ លះបង់នូវអគតិ ៤ យ៉ាង មិនញាប់ញ័រក្នុងទសពិធរាជធម៌ គប់គ្រងរាជ្យ ប្រកបដោយធម៌ បំពេញផ្លូវសុគតិបានគប់គ្រាន់ នេះទើបពេញជាអស្ចារ្យ ។ ព្រះរាជាកោសលបានអារាធនាឲ្យព្រះអង្គសំដែង; ព្រះសាស្តាក៏ទ្រង់នាំអតីតនិទានថា:

អតីតេ ។ ល ។ អហោមេវាតិ ។

អតីតេ ក្នុងកាលដែលកន្លងទៅហើយ មានក្សត្រមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទបញ្ចាល សោយរាជ្យក្នុងឧត្តរបញ្ចាលនគរ ក្នុងដែនកបិលៈ ជាស្តេចប្រកបដោយអគតិ មានសេចក្តីប្រមាទក្នុង

អកុសលធម៌ ។ ចាំងពួកជ្ជកជ្ជមាត្ស ក៏ស្ទុះតែប្រកបដោយអកុសលធម៌ចាំងអស់ ។ មហាក្សត្រនោះ ចាត់ចែងការជ្ជការមិនត្រូវតាមច្បាប់ បវេណីក្សត្រតាមដើម បណ្តាយឲ្យពួកអ្នកជ្ជការមន្ត្រីតូច-ធំ ប្លែកប្លែនរឹបជាន់ពួកស្ត្រីប្រជាដោយសួយសារអាតារ យកធនជ្ជាវតមានច្បាប់ទម្លាប់ ពួកស្ត្រីប្រជាដែលនៅកន្លែងដែនចាំងប៉ុន្ម្នាន ក៏កើតសេចក្តីក្តៅក្រហាយ រកស៊ីធ្វើការមិនបានសេចក្តីសុខ-ចំរើន, ដល់ពេលថ្ងៃនេះទៀត យកបន្ទាន់ដ៏ដែកឈើមកស្ទាស់មាត់ទ្វារផ្ទះ ហើយនាំកូនប្រពន្ធទៅនៅកន្លែងដ៏ព្រៃដូចជាពួកម្រ៉ីត ដោយខ្ជាចពជ្ជបុរសរឹបជាន់; ពេលល្ងាចទើបបាននាំកូនប្រពន្ធវិលមកផ្ទះវិញ ដល់ពេលយប់ត្រូវពួកចោរចូលមកលួចប្លន់យកទ្រព្យសម្ប្តីទៀត ឥតមានបានសុខពេលណាសោះ, ពេលថ្ងៃត្រូវពួកជ្ជបុរសរឹបជាន់, ពេលយប់ត្រូវពួកចោរប្លន់ដណ្តើមយកទ្រព្យ ។

ត្រានោះ ព្រះពោធិសត្ត្ववកើតជាវុក្ខទេវតាឈ្មោះកណ្ណ្ណ:ត្ណ្ណ: អាស្រ័យនៅខាងក្រៅនគរ ព្រះមហាក្សត្រតែងយកគ្រឿងសក្ការ:ដ៏ទក្ខ្ម ទៅបូជាកាលៗ ។ ; ពោធិសត្ត្ववដ៏ធំ:ហតុដែលកើតមានកន្លែងនគរ:ហ៊ីយ ក៏មានសេចក្តីត្រិះរិះថា ស្ដេចនេះ ចាប់តាំងពីបានសោយរាជ្យមក មានសេចក្តីប្រមាទ មិនប្រព្រឹត្តតាមច្បាប់បវេណី មិនកាន់ទសពិធរាជធម៌សោះ រមែងញ៉ាំងជនឲ្យវិនាសសាបសូន្យទៅ; បើអាត្មាអញមិនទៅជួយស្រោចស្រង់ញ៉ាំងស្ដេចនេះឲ្យបិតនៅកន្លែងធម៌ទេ ម្ចុះដាមានសេចក្តីអត្ត្ववយណា

មួយដោយពិត, ព្រោះស្តេចនេះ មានឧបការដល់អញច្រើនណាស់ គួរអញទៅទូន្មានឲ្យឋិតនៅក្នុងសុចរិតធម៌, លុះពោធិសត្វគិតដូច្នេះ ហើយក៏ហោះចូលទៅកាន់ទីសេយ្យាសន៍នៃស្តេច ហើយបញ្ចេញនូវពន្លឺស្មើភ្លើងពាសពេញទាំងប្រាសាទ ។ ស្តេចបញ្ចូលបានទតឃើញនូវពន្លឺស្មើនោះហើយក៏ត្រាស់សួរថា នរណានេះ? អ្នកឯងជាអ្វី? មកក្នុងទីនេះដោយហេតុដូចម្តេច? ពោធិសត្វតបថា បពិត្រមហារាជ ខ្ញុំព្រះអង្គជាទេវតាឈ្មោះគណ្ឌតិណ្ឌុកៈ មកដើម្បីថ្វាយឱវាទដល់ព្រះអង្គ ។ ស្តេចត្រាស់សួរថាអ្នកឯងឲ្យឱវាទដល់ខ្ញុំដូចម្តេច? ពោធិសត្វតបថា បពិត្រមហារាជ ព្រះអង្គគ្រប់គ្រងរាជ្យក្នុងនគរនេះមិនប្រកបដោយធម៌ទេ; មានសេចក្តីប្រមាទណាស់ ដែនរបស់ព្រះអង្គនេះមុខជានឹងវិនាសសាបសូន្យទៅពុំខាន; ធម្មតាស្តេចសោយរាជ្យក្នុងនគរមួយ ៗ តែមានសេចក្តីប្រមាទហើយនឹងធ្វើជាម្ចាស់ដែនពុំបានទេ, នឹងមានសេចក្តីវិនាសក្នុងបច្ចុប្បន្ននេះ, លុះដល់ទៅបរលោកនាយក៏ទៅកើតក្នុងមហានរកទៀត; មួយយ៉ាងទៀត បើមហារាជប្រមាទហើយពួកជនខាងក្នុង គឺពួកអ្នករាជការធំ-តូច ដែលធ្វើការថ្វាយព្រះអង្គក្តី ពួកជនខាងក្រៅ គឺពួករាស្ត្រប្រជាដែលជាអ្នកធ្វើកិច្ចការរកស៊ីចិញ្ចឹមជីវិត ជាអ្នករកសួយសារអាករថ្វាយព្រះអង្គក្តី ក៏សុទ្ធតែមានបមាទធម៌ទាំងអស់ ។ ព្រោះហេតុនោះ សូមព្រះអង្គតាំងព្រះទ័យឲ្យល្អកុំមានសេចក្តីប្រមាទឡើយ ។ ពោធិសត្វទូន្មានយ៉ាងនេះហើយ ទើបសំដែងធម៌ទេសនាតទៅទៀតថា:

អប្ឈមាដោ អមតំ បជំ បមាដោ មច្ចុដោ បជំ
អប្ឈមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។
មដា បមាដោ ដាយេថ បមាដា ដាយតេ ឧយោ
ឧយា ច ដោសា ដាយន្តិ មា មដោ ការត្ថសក ។
ពហ្ហ ហិ ឧត្តិយា ដិណ្ណា អត្ថំ រដ្ឋំ បមាដិដោ
អថោបិ តាមិដោ តាមា អដាតាភ អតារិដោ ។
ឧត្តិយស្ស បមត្តស្ស រដ្ឋស្មឺ រដ្ឋវឌ្ឍន
សព្ចេ ភោតា ទិដស្ស្ដន្តិ រញ្ញោ តំ ទុច្ចតេ អយំ ។
ដេស ជម្មោ មហាភដ អតិវេលំ បមជ្ជសិ
ឥដ្ឋំ ដីតំ ដនបជំ ចោភ ទិដ្ឋំសយន្តិ ដំ ។
ន តេ បុត្តា ការិស្ស្ដន្តិ ន ហិរញ្ញំ ន ជានិយំ
រដ្ឋ ទិលុម្ឈមានម្ហិ សព្ចភោតេហិ ដិយ្ឈសិ ។
សព្ចភោតបរិដិណ្ណំ ភដានំ ភាបិ ឧត្តិយំ
ញាតិមិត្តា សុហដ្ជា ច ន តំ មញ្ញន្តិ មន្តិយំ ។
ហត្ថាភេហា អដីតដ្ឋា រថិតា បត្តិតារតា
តមេវមុបដីវន្តា ន តំ មញ្ញន្តិ មន្តិយំ ។
អសំទិហិតតម្មន្តំ ពាលំ ដុម្មន្តិ មន្តិដំ
សិរ ដហតិ ដុម្មេធំ ដិណ្ណំវ ឧរតោ តថំ ។

សុសំវិហិតកម្មន្តំ ការលុដ្ឋាយី អតន្ទិតំ
សព្ពេ ភោគាកិវ ឍ្ឍន្តិ តាវ សត្ថុសកាមិវ ។
ឧបស្ស្ជ្ជ ឧមាវាជ   រដ្ឋ ជនបទេ ចរ
ឥត្ថ ទិស្ស ច សុត្ថ ច ឥ.ត ត ឥ ២ ២ ២ ២ ។

សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ពួកជនអ្នកមិនប្រមាទ ឈ្មោះថាមិនស្លាប់, ពួកជនឯណាជាអ្នកប្រមាទ ពួកជនទោះ ដូចជាស្លាប់ហើយ ។ សេចក្តីប្រមាទកើតឡើង ព្រោះសេចក្តីស្រវឹង, ការអស់ទៅ (នៃពួកញាតិជាដើម) ក៏រមែងកើតឡើង ព្រោះសេចក្តីប្រមាទ, សេចក្តីថ្នាំងថ្នាក់ក្នុងចិត្ត រមែងកើតឡើង ព្រោះការអស់ទៅ (នៃទ្រព្យនិងយស ព្រោះហេតុនោះ) បពិត្រសម្តេចជាចម្បងក្នុងជនដ ព្រះអង្គកុំប្រមាទ.ឡើយ ។ ពួកក្សត្រជាច្រើនអង្គ បើមានសេចក្តីប្រមាទហើយ រមែងសាបសូន្យចាកប្រយោជន៍ទាំងដែន ; ចំណែកខាងពួកមនុស្ស ក៏រមែងសាបសូន្យចាកស្រុក, ពួកអ្នកបួសក៏សាបសូន្យ (ចាកកិច្ចការរបស់អ្នកបួស), ពួកគ្រហស្ថក៏សាបសូន្យ (ចាកកិច្ចការរបស់គ្រហស្ថ) ។ បពិត្រសម្តេចជាទ្រកញ្ជ្ញាងដែនឲ្យចំរើន ភោគសម្បត្តិទាំងអស់ទាបស់ក្សត្រជាអ្នកប្រមាទ រមែងវិនាសទៅដោយពិត, សេចក្តីវិនាសនោះ គេហៅថាជាទុក្ខរបស់ស្តេច ។ បពិត្រមហាពជ សេចក្តីប្រមាទនេះ មិនមែនជាធម្ម (ទាបស់ពួកស្តេចទេ) ព្រះអង្គ

ប្រមាទហួសពេកណាស់ ពួកចោរនឹងកំចាត់បង់នូវជនបទដែលសម្បូណ៌
ថ្កុំថ្កើង (ដោយបាយទឹកមាសប្រាក់) នោះបាន ៗ បុរីរបស់ព្រះ
អង្គមិនមានទេ ទាំងប្រាក់ក៏មិនមាន ទាំងជាទក៏មិនមានដែរ, កាល
បើចោរប្លន់រាស្ត្រ (យ៉ាងនេះ) ព្រះអង្គនឹងសាបសូន្យចាកភោគសម្បទ
គ្រប់យ៉ាង ៗ ពួកញាតិ មិត្ត សំឡាញ់ ក៏មិនស្គាល់នូវស្តេចឬក្សត្រ
ដែលសាបសូន្យចាកភោគសម្បទទាំងពួង ដែលគួរស្គាល់ (ថាជាស្តេច)
បានទេ ៗ ពួកពលដំរី ពួកសេនា ពលរថ ពលថ្មើរជើង នឹងពួក
កម្មករ ដែលអាស្រ័យចិញ្ចឹមជីវិតនឹងស្តេចនោះឯង ក៏មិនស្គាល់នូវ
ស្តេចដែលគួរស្គាល់បាន ៗ សិរីគឺយសសម្បត្តិ រមែងលះបង់បុគ្គល
ពាលអ្នកមិនចេះចាត់ចែងការងារ មានគំនិតអាក្រក់អាប់ឥតប្រាជ្ញា ដូច
ជាពស់លះបង់នូវសំណកចាស់ ៗ ភោគសម្បទទាំងអស់ រមែងចំរើនដល់
បុគ្គលអ្នកចេះចាត់ចែងការងារដោយល្អ ក្រោកឡើងទាន់កាលសម័យ
ជាអ្នកមិនខ្ជិលច្រអូស ដូចជាហ្វូងគោព្រមទាំងគោឧសភ ៗ បពិត្រ
មហារាជ សូមព្រះអង្គយាងទៅកាន់ស្រុកក្រៅចាំស្តាប់ (ពាក្យរាស្ត្រ)
ក្នុងដែន នឹងជនបទរបស់ព្រះអង្គ លុះបានឃើញឬបានឮក្នុងដែននឹង
ជនបទនោះហើយ តទៅសូមព្រះអង្គធ្វើតាមដំណើរនោះចុះ ៗ

ពោធិសត្វថ្វាយឱវាទដល់ស្តេចដោយគាថា ១១ នេះហើយ ក៏ទូល
ថែមទៀតថា សូមឲ្យព្រះអង្គយាងទៅឲ្យឆាប់ៗ ទៅកុំបង្អង់ឡើយ ៗ
ទេវតាថាហើយក៏ត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួនវិញ ៗ

ស្ដេចបានទ្រង់ព្រះសណ្ដាប់ពាក្យទេវតាពោលប្រាប់យ៉ាងនេះ ហើយក៏មានសេចក្ដីតក់ស្លុត លុះព្រឹកឡើងក៏ប្រគល់រាជសម្បត្តិឲ្យអាមាត្យហើយក៏ក្លែងភេទធ្វើដូចជាមនុស្សធម្មតា ចេញចាកព្រះរាជវាំងទៅតាមផ្លូវខាងលិចជាមួយនឹងបុរោហិតម្នាក់ សំដៅទៅកាន់ស្រុកមួយចម្ងាយផ្លូវ ១ យោជន៍ ។ ស្រុកនោះមានបុរសចាស់ម្នាក់ កំពុងទាញបន្លាយកមកស្ទាស់ទ្វាររបងផ្ទះ ហើយក៏នាំប្រពន្ធកូនចូលទៅនៅក្នុងព្រៃ លុះពេលល្ងាចពួកកជបុរសចៀសចេញអស់ទៅ ទើបនាំកូនប្រពន្ធមកវិញ ដើរមកដល់មាត់ទ្វាររបងបន្លាក៏មុតជើងគាត់ ។ អង្គុយដោះបន្លាបណ្ដើរដេរស្ដេចបណ្ដើរដោយពាក្យថា:

សីសំ វេធតុ បញ្ចាលោ សង្គាមេ សរមប្បិតោ
យថាហមជ្ជ វេធមិ កណ្ដកេន សមប្បិតោ ។

ខ្ញុំអញដែលត្រូវបន្លាមុត ហើយដឹងច្បាស់ក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យស្ដេចបញ្ចាល (ក្នុងនគរនេះ) ត្រូវសរមុតក្នុងសង្គ្រាម ហើយដឹងច្បាស់យ៉ាងនេះដែរ ។

ចួនជាពេលនោះ ស្ដេចនឹងបុរោហិតក៏នៅជិតបុរសចាស់នោះដែរ, បុរោហិតឮពាក្យបុរសដេរស្ដេចដូច្នោះហើយ ក៏សួរថា:

ជិណ្ណោ ទុព្វលចក្ខុសិ ន រូបំ សាធុ បស្សសិ
កឹ តត្ថ ព្រហ្មទត្តស្ស យំ តំ មគ្គេយ្យ កណ្ដកោ ។

អ្នកជាមនុស្សចាស់មានភ្នែកទុព្វល មើលរូបមិនឃើញបានដោយស្រួលទេ បន្ទាមុខជើងអ្នកឯង ដោយហេតុឯណា ទោសរបស់ស្តេចព្រហ្មទត្តចំពោះហេតុនោះតើដូចម្តេច (ទើបអ្នកឯងជេរស្តេចវិញ) ។ បុរសចាស់ឆ្លើយថា:

ពហ្វេត្ថ ព្រហ្មទត្តស្ស សោហំ មគ្គស្មិំ ព្រាហ្មណ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។
រត្តិញ្ច ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មិំ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។
ឯតាទិសេ ភយេ ជាតេ ភយដ្ដា តាត មាណវ
និល្លេនកានិ កុព្វន្តិ វនេ អាហត្វា កណ្ដកំ ។

ម្នាលព្រាហ្មណ៍ ទោសរបស់ស្តេចព្រហ្មទត្តមានៈច្រើនណាស់ក្នុងហេតុនេះគឺខ្ញុំដែលដើរកន្លង (មានបន្ទាក់ត្រូវបន្ទាមុខ) ទាំងពួកអ្នកជនបទ គឺៈ ប្តូមិនរក្សា បេះតែឲ្យបៀតបៀនដោយពលិកម្ម (សួយសារអាករ) មិនប្រកបដោយធម៌ ។ ពិតណាស់ក្នុងវេលាយប់ ពួកចោរដើរប្លន់ (អ្នកស្រុក) វេលាថ្ងៃ ពួកអ្នកពាក់ព្រតគឺពួកអ្នករាជការក៏ប្លន់ (កស្រៃថែមទៀត ព្រោះតែ) ស្តេចខូចកាចសោយរាជ្យក្នុងដែន ទើបមានជនមិនប្រកបដោយធម៌ច្រើនណាស់ ។

(នៅមានត)

លោកគ្រូព្រះអាចារ្យ ប៉ាង-ទាត់
រៀបរៀង (ភមក)

"នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម្មជាតគ្រឿងរំលត់ទុក្ខ
នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់សេចក្តីរំលត់ទុក្ខ នេះចុះ" ។

ឆ្នាំ.ភ.ស. ១៩-៤៤-១ពីរ០

ទ្រង់ត្រាស់ដឹងដ៏វិញលោកគឺអរិយសច្ច ៤

ម្នាលភិក្ខុទាំងឡាយ! លោក[1] ជាសភាពគឺតថាគតត្រាស់ដឹងហើយ
តថាគតដកខ្លួនហើយចេញចាកលោក, ម្នាលភិក្ខុទាំងឡាយ! ហេតុប្រជុំ
កើតឡើងនៃលោក ជាសភាពគឺតថាគតត្រាស់ដឹងហើយ ហេតុប្រជុំ
កើតឡើងនៃលោក ជាសភាពគឺតថាគតលះបង់ចោលហើយ, ម្នាលភិក្ខុ
ទាំងឡាយ! ធម្មជាតគ្រឿងរំលត់លោក ជាសភាពគឺតថាគតត្រាស់ដឹង
ហើយ ធម្មជាតគ្រឿងរំលត់លោកជាសភាពគឺតថាគតធ្វើឲ្យជាក់ច្បាស់
ហើយ, ម្នាលភិក្ខុទាំងឡាយ! សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់
លោកជាសភាពគឺតថាគតត្រាស់ដឹងហើយ សេចក្តីប្រតិបត្តិជាដំណើរ
ទៅកាន់ទីរំលត់លោកជាសភាពគឺតថាគតចំរើនឲ្យច្រើនហើយ ។ ម្នាល
ភិក្ខុទាំងឡាយ! បុគ្គលណា ដែលលោកព្រមទាំងទេវៈលោក មារលោក
ព្រហ្មលោក ពួកសត្វព្រមទាំងសមណៈព្រាហ្មណ៍ ទាំងទេពតានទាំងមនុស្ស

---

១ ពាក្យថា លោក ក្នុងទីនេះជាឈ្មោះនៃសេចក្តីទុក្ខ គឺតួទុក្ខហ្នឹងឯង ។

ចានយើញហើយ ចានឮហើយ ចានពាល់ត្រូវហើយ ចានដឹងហើយ ចានដល់ហើយ ចានអនុញ្ញាតហើយ ដោយចិត្ត, របស់នោះតថាគត ចានត្រាស់ដឹងអស់ហើយដោយប្រពៃ ព្រោះហេតុនោះកើត ចានជាពួកអ្នកប្រាជ្ញហៅថា: "តថាគតដូច្នេះ" ។

ឧត្តរ. អ. ២១-៧០-២៣

ទ្រង់បន្ទូលសីហនាទ ប្រកាសចតុរារ៉ាយសច្ច

ម្នាលភិក្ខុពាន់ឆ្នាំ! មិគជាសម្ងាត់ ពេលសាយណ្ហសម័យ ចេញពីទីអាស្រ័យហើយ មានតត្តកាយ ដាក់មៀងមើលទិសពាន់ជុនជុំ ជុំវិញ ចន្ទ្រីសីហនាទ ៣ ដងរួចហើយ ដើរចូលចេញទៅដើម្បីទីគោចរ, ម្នាលភិក្ខុពាន់ឆ្នាំ! ពួកសត្វតិរច្ឆានពាន់ឆ្នាំ ចានឮសីហនាទ ហើយ សត្វពាន់ឆ្នាំនោះ ក៏ភ័យតក្ក្ដមាស្ងុតនន្ទ្ធ៍ តាយ សត្វដែលអាស្រ័យនន្ទ្ធ៍ក៏ចូលនន្ទ្ធ សត្វដែលអាស្រ័យទឹកក៏លោតចុះទឹក សត្វដែលនៅព្រៃក៏ចាលចូលព្រៃ ពួកសត្វបក្សីក៏ហើរឡើងកាន់អាកាស, ពួកដំរីស្ពាយ ក្ដន្ត្រ ស្រកនិតមកជានិច្ចពាន់ឆ្នាំ ដែលគេចងដោយត្រ ព័ត្ត្ដដ៏ម៉ាំ ពាន់ឆ្នាំ ក៏ភ័យតក់ស្ងុតលេចអាចម៍លេចនាម ចាលផ្ដាច់ចំណងពាន់-ឆ្នាំនោះហើយ រត់ទៅផ្ដួសផ្ដាសសព្ទ ១ ១ ខ្ជួន, ម្នាលភិក្ខុពាន់ឆ្នាំ! មិគជាសម្ងាត់ ជាសត្វមានបុណ្ឍ្ញ ប្រ ជ្ញ មានសក្ដិធំ មានអានុភាពកម្ចិនជាងពួកសត្វតិរច្ឆានពាន់ឆ្នាំ ដោយអាការយ៉ាងនេះឯង ។

ម្នាលភិក្ខុតាំងឡាយ! ពីដូចគ្នា ការណ៍ណាតថាគតកើតឡើងក្នុងលោក ជាព្រះអរហន្ត ជាព្រះសម្មាសម្ពុទ្ធ សម្បូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្ញាបចាស់លោក ជាសារថីអ្នកប្ដូនានទ្ទរបុរស ជាសាស្ដានៃទេពតានិងមនុស្សតាំងឡាយ ជាព្រះពុទ្ធ ទ្រង់មានដោតតថាគតនោះ សំដែងធម៌ថា: "សក្កាយៈគឺទុក្ខដូច្នេះ សក្កាយសមុទយៈ គឺហេតុប្រជុំកើតឡើងនៃសក្កាយដូច្នេះ សក្កាយនិរោធៈ គឺធម៌ជាគ្រឿងរំលត់សក្កាយៈដូច្នេះ សក្កាយនិរោធគាមិនីបដិបទា គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់សក្កាយៈដូច្នេះ" ម្នាលភិក្ខុតាំងឡាយ! ពួកទេពតាតាំងឡាយដែលមានអាយុវែង មានពណ៌ល្អ មានសេចក្ដីសុខច្រើនបានតម្រេកអស់កាលដ៏យូរ ក្នុងវិមានដ៏ត្ពាត់ត្ពស់តាំងឡាយ, ពួកទេពតាតាំងឡាយនោះ បានស្ដាប់ធម៌តថាគតហើយ ក៏ភ័យតក្ក្ដមស្ទុតកាយស្ទុតចិត្ដដោយច្រើន បានដឹងខ្លួនថា: "ពុគ្គាយើងអើយ! យើងតាំងឡាយជាបុគ្គលមិនទៀងទាត់ ក៏ចចូលគ្នាយល់ថាយើងទៀងទាត់, ពុគ្គាយើងអើយ! យើងតាំងឡាយជាបុគ្គលមិនបានតម្រេក ក៏ចចូលគ្នាយល់ថាយើងបានតម្រេក, ពុគ្គាយើងអើយ! យើងតាំងឡាយជាបុគ្គលមិនមាំមួន ក៏ចចូលគ្នាយល់ថាយើងមាំមួន, ពុគ្គាយើងអើយ! យើងតាំងឡាយជាបុគ្គលមិនទៀង មិនបានតម្រេកមិនមាំមួន ហើយដល់ទីកន្លែងយ៉ាងនេះ (គឺដល់ទុក្ខ) ដូច្នេះ" ម្នាលភិក្ខុតាំងឡាយ! តថាគតជាបុគ្គលមានបុណ្ដ្ដិ្ដច្រើន

មានសក្តិធំ មានអានុភាពប្រើន ជាធសត្វលោក ព្រមទាំងទេវលោក ដោយអាការយ៉ាងនេះឯង ។

ចតុក្ក. អ. ២១ ៦៤-៣៣

ទ្រង់ប្រកាសអនុត្តរធម្មចក្រ ដែលបុគ្គលណាម្ហយប្រកាសមិន បានតាព្រៃតិសិបតនមិគទាយវ៉ន

— ម្នាលភិក្ខុទាំងឡាយ! ធម្មចក្រដ៏ប្រសើរ ដែលតថាគតជាអរហន្ត សម្មាសម្ពុទ្ធ ឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ៉ន ជិតក្រុងពាកណសី ជាធម្មចក្រដែលសមណក្តី ព្រាហ្មណ៍ក្តី ទេពតាក្តី មារក្តី ព្រហ្មក្តី នរណាម្ហយក្តី ក្នុងលោក ឲ្យប្រព្រឹត្តទៅមិនបាន គឺការប្រាប់ ការសំដែង ការបញ្ជាក់ ការតែងតាំង ការបើក ការចែក នឹងការធ្វើឲ្យងាយនូវ អរិយសច្ច ៤ ។ អរិយសច្ច ៤ តើដូចម្តេច? គឺការប្រាប់ ការសំដែង ការបញ្ជាក់ ការតែងតាំង ការបើក ការចែក នឹងធ្វើឲ្យងាយនូវទុក្ខអរិយសច្ច ១, នូវទុក្ខសមុទយអរិយសច្ច ១ នូវទុក្ខនិរោធអរិយសច្ច ១ នូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ: ធម្មចក្រដ៏ប្រសើរ ដែលតថាគតជាអរហន្តសម្មាសម្ពុទ្ធឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ៉ន ជិតក្រុងពាកណសី ដូច្នេះឯង ។

ម ឧបរិ សច្ចវិភង្គសូត្រ ២៨.៦០១-១៣៤

វិជ្ជាដែលទ្រង់មិនតាំយកមកប្រកាស នៅមានប្រើនណាស់

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ប្រថាប់ក្នុងព្រៃសីសបាទ្រៀបក្រុងកោសម្ពី ។ កាលនោះ ព្រះដ៏មានព្រះភាគទ្រង់ក្តាប់ស្ទឹកឈើសីសបាបន្តិចក្នុងព្រះហស្ត ហើយហៅភិក្ខុតាំងឡាយមក ទើបត្រាស់សួរថា ម្នាលភិក្ខុតាំងឡាយ? អ្នកតាំងឡាយសំគាល់ដូចម្តេច? ស្ទឹកសីសបាដែលតថាគតក្តាប់នោដៃនេះ នឹងស្ទឹកដែលសល់នៅលើដើម ឯណាប្រើនជាងឯណា? បពិត្រព្រះដ៏មានដោគ ស្ទឹកសីសបាដែលទ្រង់ក្តាប់នូវព្រះហស្តនេះមានចំនួនតិចណាស់ ដែលសល់នៅលើដើមមានចំនួនប្រើនណាស់ ។

ម្នាលភិក្ខុតាំងឡាយ ក៏ដូចគ្នា ធម៌ដែលតថាគតបានត្រាស់ដឹងមានចំនួនប្រើនណាស់ ដែលសល់នៅតថាគត មិនបានតាំមកប្រកាសប្រាប់អ្នកតាំងឡាយ ។ ព្រោះហេតុអ្វី បានជាតថាគតមិនតាំមកប្រកាសប្រាប់អ្នកតាំងឡាយ ម្នាលភិក្ខុតាំងឡាយ! ព្រោះថាធម៌នេះ មិនប្រកបដោយប្រយោជន៍ មិនមែនជាទាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនៀយណាយ ដើម្បីប្រាសចាកតម: ដើម្បីសេចក្តីរំលត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីត្រាស់ដឹងនឹងដើម្បីព្រះនិព្វានទេ ព្រោះហេតុនេះឯង បានជាតថាគតមិនសំដែងប្រាប់អ្នកតាំងឡាយ ។

វិជ្ជាដែលទ្រង់នាំមកប្រកាស សុទ្ធតែជាធម៌នាំឲ្យរួចចាកទុក្ខ

ម្នាលភិក្ខុពាំងឡាយ ! ធម៌អ្វីទៅ ដែលតថាគតយកមកប្រាប់អ្នកពាំងឡាយ? ធម៌ដែលតថាគតយកមកប្រាប់អ្នកពាំងឡាយសុទ្ធតែជាសេចក្តីពិតដ៏ប្រសើរ គឺ: នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាជំណើរទៅកាន់សេចក្តីរំលត់ទុក្ខ ។ ម្នាលភិក្ខុពាំងឡាយ! ហេតុអ្វីក៏តថាគត សំដែងប្រាប់ជូបសេចក្តីពិតដ៏ប្រសើរពាំងឡាយនេះ? ម្នាលភិក្ខុពាំងឡាយ ! ព្រោះថាសេចក្តីពិតដ៏ប្រសើរពាំងឡាយ នេះ ប្រកបដោយប្រយោជន៍ ជាទាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគ: ដើម្បីសេចក្តីរំលត់ទុក្ខ ដើម្បីសេចក្តីរម្ងាប់ ដើម្បីសេចក្តីដឹងដើម្បីត្រាស់ដឹងនឹងដើម្បីព្រះនិព្វាន ព្រោះហេតុនោះ ទើបតថាគតនាំមកប្រកាសប្រាប់អ្នកពាំងឡាយ ។

មហាវា. សំ. ១៩. ៥៤៧. ១៣១៤.

(នៅមានត)